THE SCHOOL DISTRICT OF PHILADELPHIA



# ក្រមសីលធម៌

## 2024-2025

ភាសាខ្មែរ

# តារាងមាតិកា


3 សៀវភៅបញ្ជីទំនាក់ទំនងការិយាល័យ School District of Philadelphia

4 ការណែនាំពីក្រុមសីលធម៌

5 ទំនួលខុសត្រូវរបស់សមាជិកសហគមន៍

6 វត្តមានសិស្ស

9 បទបញ្ញត្តិផ្ទៃក្នុងអំពីការស្លៀកពាក់

9 ការបង្រៀនតាមអនឡាញ និងឧបករណ៍អេឡិចត្រូនិក

10 ការគាំទ្រ និងសិទ្ធិរបស់សិស្ស និងអាណាព្យាបាល

14 ការប្រមាថ ការបៀតបៀន ការរើសអើង និងចំណងជើង IX

15 ការស៊ើបអង្កេត

15 អាកប្បកិរិយា និងវិន័យរបស់សិស្ស

21 ការបង្វែរ ការបញ្ជូនបន្តរបស់នាយកដ្ឋានប៉ូលិសក្រុង Philadelphia

23 ឧបសម្ព័ន្ធ - ម៉ាទ្រីសអាកប្បកិរិយា

# សៀវភៅបញ្ជីទំនាក់ទំនង School District of Philadelphia

| សៀវភៅបញ្ជីទំនាក់ទំនងការិយាល័យ School District of Philadelphia | |
|---|---|
| **មជ្ឈមណ្ឌលអប់រំ Constance E. Clayton**<br>440 North Broad Street, Philadelphia, PA 19130<br>9:00 ព្រឹក - 5:00 ល្ងាច \| មិនចាំបាច់ណាត់ជួប | 215-400-4000<br>អ្នកនិយាយភាសាអង់គ្លេស/អេស្ប៉ាញ<br>8:30 ព្រឹក - 4:30 ល្ងាច<br><br>ខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់ភាសាបន្ថែម៖<br>philasd.org/face/contact<br>ASK@philasd.org |
| នាយកដ្ឋានសេវាកម្មសិក្សា | 215-400-4200 |
| ការចូលរួមរបស់គ្រួសារ និងសហគមន៍ | 215-400-4180 |
| បរិយាកាស និងវប្បធម៌សាលារៀន | 215-400-4870 |
| មជ្ឈមណ្ឌលភ្ជាប់ទំនាក់ទំនងឡើងវិញ | 215-400-6700 |
| ការអប់រំពិសេស និងអ្នកសិក្សាចម្រុះ | 215-400-4170 |
| ការចុះឈ្មោះសិស្ស និងការដាក់សិស្សឲ្យរៀន | 215-400-4290 |
| សិទ្ធិ និងទំនួលខុសត្រូវរបស់សិស្ស | 215-400-4830 |
| ការដឹកជញ្ជូន | 215-400-4350 |
| ការការពារ និងអន្តរាគមន៍ | 215-400-4930 |
| សេវាកម្មសុខភាពសិស្ស | 215-400-4920 |
| សុវត្ថិភាពសាលារៀន | 215-400-6000 |
| **ធនធាន និងព័ត៌មានទំនាក់ទំនងសំខាន់ៗផ្សេងទៀត** | |
| មេធាវី Safe Schools Advocate រដ្ឋ Pennsylvania | 1-877-730-6315 |
| ខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់បញ្ហាការប្រមាថ | 215-400-SAFE (7233) |
| ខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់ការរំលោភបំពានលើកុមារ | 1-800-932-0313 |
| បណ្តាញសង្គ្រោះជីវិតសម្រាប់បញ្ហាការធ្វើអត្តឃាត និងវិបត្តិ | ចុចលេខ 988 |
| ខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់ការរំលោភបំពានក្នុងគ្រួសារនៃរដ្ឋ Philadelphia | 1-866-723-3014 |
| ធនធាន LGBTQIA | philasd.org/studentrights/#lgbt<br>healthymindsphilly.org |
| ការកាត់បន្ថយអំពើហិង្សា និងធនធានសម្រាប់ជនរងគ្រោះ | cap4kids.org |
| ធនធានសម្រាប់សុខភាពផ្លូវចិត្ត ការបាក់ស្បាត និងការថែទាំខ្លួនឯង | philasd.org/prevention |
| ពិពិធភាព សមធម៌ និងបរិយាបន្ន | philasd.org/dei/ |




## ការណែនាំអំពីក្រមសីលធម៌

School District of Philadelphia ប្តេជ្ញាបង្កើត និងរក្សាបរិយាកាសសាលារៀនដែលមានសុវត្ថិភាព និងមានការគាំទ្រ ដែលជាអំណោយផលដល់ការបង្រៀន និងការរៀន។ មណ្ឌលសិក្សាធិការខិតខំអភិវឌ្ឍភាពជាដៃគូប្រកបដោយអត្ថន័យជាមួយមាតាបិតា/អាណាព្យាបាល និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីឱ្យយើងអាចធ្វើការជាមួយគ្នាដើម្បីជំរុញការរីកចម្រើនផ្នែកការសិក្សា សង្គម និងសតិអារម្មណ៍ចំពោះសិស្សទាំងអស់គ្នា។ គោលដៅរបស់មណ្ឌលសិក្សាធិការគឺធានាថាសិស្សទាំងអស់មានធនធានចាំបាច់ ដើម្បីបញ្ចប់ការសិក្សា និងទទួលបានជោគជ័យក្នុងនាមជាពលរដ្ឋដែលចូលរួមយ៉ាងពេញលេញរបស់ពិភពលោក។

គោលបំណងនៃក្រមសសីលធម៌គឺដើម្បី៖

1. គូសបញ្ជាក់ពីការរំពឹងទុកច្បាស់លាស់សម្រាប់សមាជិកសហគមន៍សាលារៀនទាំងអស់
2. ផ្តល់ព័ត៌មានជុំវិញសិទ្ធិ និងការគាំទ្ររបស់សិស្ស និងមាតាបិតា/អាណាព្យាបាល
3. បំពាក់បំប៉នបុគ្គលិកអំពីគោលការណ៍ណែនាំសម្រាប់ដោះស្រាយបញ្ហាអាកប្បកិរិយារបស់សិស្ស
4. School District of Philadelphia (មណ្ឌលសិក្សាធិការ) ប្រឹងប្រែងលុបបំបាត់ការអនុវត្តវិន័យមិនស្មើភាពសម្រាប់សិស្សស្បែកខ្មៅ និងសិស្សស្បែកពណ៌ត្នោត ដូច្នេះហើយ ក្រមសីលធម៌នេះជំរុញឱ្យមានជម្រើសជំនួសចំពោះវិន័យមិនឱ្យរៀន។

## តើក្រមសីលធម៌អនុវត្តនៅពេលណា?

ក្រមសីលធម៌អនុវត្តចំពោះសមាជិកសហគមន៍សាលារៀន ខណៈពេលដែលពួកគេនៅក្នុងសាលារៀន និង/ឬនៅឯសកម្មភាពដែលឧបត្ថម្ភដោយសាលារៀន ដូចជាកម្មវិធី ឬដំណើរទស្សនកិច្ចរបស់ថ្នាក់រៀន។ ក្រមសីលធម៌ក៏អនុវត្តផងដែរចំពោះសិស្សទាំងអស់ ខណៈពេលដែលពួកគេកំពុងធ្វើដំណើរទៅ និងមកពីសាលារៀន ដោយប្រើមធ្យោបាយធ្វើដំណើរណាមួយ (ដើរ ជិះឡានក្រុង SEPTA ។ល។)។ ជាចុងក្រោយ ក្រមសីលធម៌អនុវត្តចំពោះការប្រព្រឹត្តដែលកើតឡើងក្រៅសាលារៀន តាមអនឡាញ និង/ឬក្រោយម៉ោងសិក្សា (រួមទាំងថ្ងៃចុងសប្តាហ៍) ប្រសិនបើការប្រព្រឹត្តប៉ះពាល់ខ្លាំងដល់សហគមន៍សាលារៀន (មានន័យថាការប្រព្រឹត្តមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ឬច្រើនគួរសម)។ សាលារៀននីមួយៗត្រូវតែអនុវត្តតាមក្រមសីលធម៌របស់មណ្ឌលសិក្សាធិការ។

# ទំនួលខុសត្រូវរបស់សមាជិកសហគមន៍

សមាជិកសហគមន៍សាលារៀននីមួយៗដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងមានលក្ខណៈគាំទ្រសម្រាប់សិស្សរបស់យើង។ ទំនួលខុសត្រូវទាំងនេះមានដូចជា៖

### ទំនួលខុសត្រូវរបស់មនុស្សគ្រប់រូប

- •គោរពសិទ្ធិសមាជិកទាំងអស់នៃសហគមន៍សាលារៀន។
- •រក្សាបរិយាកាសសាលារៀនប្រកបដោយភាពវិជ្ជមាន ដោយការទទួលខុសត្រូវ បរិយាបន្ន និងការសហការ។
- អនុវត្តការវិនិច្ឆ័យល្អ ដើម្បីទប់ស្កាត់មិនឱ្យឧប្បត្តិហេតុតូចតាចក្លាយជាបញ្ហាធំ។

### ទំនួលខុសត្រូវរបស់សិស្ស

- ព្យាយាមស្វែងយល់ និងអនុលោមតាមការរំពឹងទុករបស់ថ្នាក់រៀន កម្រិតសាលារៀន និងមណ្ឌលសិក្សាធិការ។
- ទទួលខុសត្រូវខ្លួនឯងដើម្បីត្រិះរិះគិតអំពីឥរិយាបថ និងទទួលកំហុស។
- រក្សាការទទួលខុសត្រូវ ដើម្បីខិតខំទៅរកភាពរីកចម្រើន និងភាពជោគជ័យ។
- ស្វែងរកការលើកទឹកចិត្ត និងភាពរីករាយក្នុងការរៀនសូត្រ ដើម្បីផ្តោតលើភាពជោគជ័យក្នុងការសិក្សា។
- រាយការណ៍ពីជម្លោះ និង/ឬកង្វល់ទៅកាន់សមាជិកបុគ្គលិកសាលារៀន។
- សុំជំនួយ និងការគាំទ្រនៅពេលណាដែលត្រូវការ។

### ទំនួលខុសត្រូវរបស់សមាជិកបុគ្គលិកសាលារៀន

- •បង្កើត និងរក្សាបរិយាកាសស្វាគមន៍សម្រាប់សិស្សានុសិស្ស មាតាបិតា/អាណាព្យាបាល និងភ្ញៀវទាំងអស់។
- •បង្រៀន និងបង្រៀនឡើងវិញឱ្យបានច្បាស់លាស់ពីការរំពឹងទុករបស់សហគមន៍សាលារៀន។
- •បង្ហាញអាកប្បកិរិយាសមរម្យ និងជំនាញសង្គមអារម្មណ៍ដល់សិស្ស។
- •ធ្វើការជាដៃគូជាមួយមាតាបិតា/អាណាព្យាបាលតាមរយៈការទំនាក់ទំនងសកម្មាមួយពួកគេ និងការឆ្លើយតបនឹងសំណើប្រជុំក្នុងរយៈពេលពីរ (2) ថ្ងៃធ្វើការ។
- •ធានាថាសិស្សទាំងអស់មានលទ្ធភាពទទួលបានឱកាសទាំងអស់នៅសាលារៀនដោយស្មើភាពគ្នា និងមិនរងការបៀតបៀន ឬការហាមមិនឱ្យចូលដោយមិនស្មើភាព ស្របតាមការប្តេជ្ញារបស់មណ្ឌលសិក្សាធិការក្នុងការលុបបំបាត់ការរើសអើងជាតិសាសន៍ជាប្រព័ន្ធដែលរារាំងដល់លទ្ធផលសិក្សារបស់សិស្ស។
- •បណ្តុះ និងរក្សាបរិយាកាសរៀនសូត្រដែលនាំទៅរកភាពជោគជ័យក្នុងការសិក្សា។
- •ស៊ើបអង្កេត និងចងក្រងឯកសារឱ្យបានហ្មត់ចត់ចំពោះការរំលោភបំពានលើក្រមសសីលធម៌ដែលត្រូវបានចោទប្រកាន់នៅក្នុងប្រព័ន្ធព័ត៌មានសិស្សរបស់មណ្ឌលសិក្សាធិការ។
- •ឆ្លើយតបទៅនឹងការរំលោភបំពានលើក្រមសីលធម៌ដោយមានអន្តរាគមន៍ និងការគាំទ្រ ដើម្បីដោះស្រាយបញ្ហាអាកប្បកិរិយារបស់សិស្ស។
- •រាយការណ៍ពីការសង្ស័យសមហេតុផលអំពីការមិនយកចិត្តទុកដាក់ ឬការរំលោភបំពានលើកុមារ ទៅកាន់ខ្សែទូរសព្ទទាន់ហេតុការណ៍សម្រាប់ការរំលោភបំពានលើកុមារ។
- រក្សាការសម្ងាត់អំពីកំណត់ត្រាសិស្ស។

### ទំនួលខុសត្រូវរបស់មាតាបិតា/អាណាព្យាបាល

- គាំទ្រគោលនយោបាយរបស់មណ្ឌលសិក្សាធិការ ក្រមប្រតិបត្តិ និងសៀវភៅណែនាំរបស់សាលារៀន។
- ផ្តល់អាទិភាពឱ្យការចូលរៀន និងសង្កត់ធ្ងន់លើសារៈសំខាន់នៃការបង្ហាញខ្លួននៅសាលារៀនរាល់ថ្ងៃ ត្រៀមខ្លួនចូលរួម និងត្រៀមខ្លួនរៀនសូត្រ។
- ធ្វើជាអ្នកចូលរួមសកម្មនៅក្នុងការអប់រំកូនរបស់អ្នកតាមរយៈការប្រាប់ និងឆ្លើយតបនឹងការផ្សព្វផ្សាយរបស់សាលារៀនទាក់ទងនឹងតម្រូវការ កង្វល់ និងភាពជោគជ័យរបស់កូន។
- សហការជាមួយបុគ្គលិកសាលារៀន និងភាគីពាក់ព័ន្ធ នៅពេលចាំបាច់ ដើម្បីធានាថាកូនរបស់អ្នកទទួលបានការគាំទ្រសមស្របដែលចាំបាច់ដើម្បីជោគជ័យ។
- គោរពការសម្រេចចិត្តដែលថ្នាក់ដឹកនាំសាលារៀនបានធ្វើ ទោះបីជាអ្នកមិនយល់ស្របនឹងពួកគេក៏ដោយ។
- បង្ហាញអាកប្បកិរិយាសមរម្យ និងជំនាញសង្គមអារម្មណ៍ដល់សិស្ស។
- រួមចំណែកធ្វើឱ្យបរិយាកាសសាលារៀនមានសុវត្ថិភាពតាមរយៈការស្វែងរកការដោះស្រាយជម្លោះដោយសន្តិវិធី។

### ទំនួលខុសត្រូវរបស់ភ្ញៀវចូលទស្សនាសាលារៀន

- រៀបចំពេលវេលាចូលទស្សនាសាលារៀនជាមុន នៅពេលណាដែលអាចធ្វើបាន។
- នៅពេលមកដល់សាលារៀន ត្រូវរាយការណ៍ទៅការិយាល័យធំដើម្បីចុះឈ្មោះចូល បញ្ជាក់មូលហេតុសម្រាប់ការចូលទស្សនា បង្ហាញបណ្ណសម្គាល់ខ្លួនមានរូបថត (បើអាច) និងទទួលការអនុញ្ញាតពីបុគ្គលិក ដើម្បីបន្តដំណើរការទស្សនកិច្ចនេះ។
- សូមយល់ថាថ្នាក់ដឹកនាំសាលាមិនអាចធានាឱ្យមានជំនួបនៅពេលទស្សនាដោយមិនបានគ្រោងទុកមុនបានទេ។
- ចៀសវាងប្រើភាសាបែបប្រមាថ និងរំលោភបំពាន។
- ចៀសវាងប្រើកម្លាំងបាយប្រឈមមុខដាក់គ្នា និងចៀសវាងលើកទឹកចិត្ត/ញុះញង់ឱ្យប្រើកម្លាំងបាយបប្រឈមមុខដាក់គ្នា។
- ចៀសវាងយកអាវុធគ្រប់ប្រភេទចូលបរិវេណសាលារៀន។ ការយកអាវុធគ្រប់ប្រភេទចូលបរិវេណសាលារៀន នឹងនាំឱ្យមានការមិនឱ្យចូលសាលារៀនជាបន្ទាន់។

មាតាបិតា/អាណាព្យាបាលណាដែលមិនអនុលោមតាមទំនួលខុសត្រូវរបស់សមាជិកសហគមន៍ដូចបានរៀបរាប់ខាងលើ គេអាចនឹងមិនឱ្យចូលសាលារៀនរយៈពេលបី (3) ខែ ឬមួយឆ្នាំពេញ អាស្រ័យលើកាលៈទេសៈ។ ការមិនឲ្យចូលសាលារៀន អាចគ្រាន់តែធ្វើឡើងដោយលិខិតមិនឲ្យចូលសាលារៀនជាលាយលក្ខណ៍អក្សរ ដែលចេញដោយសាលារៀនជូនទៅមាតាបិតា/អាណាព្យាបាលប៉ុណ្ណោះ។ បើអាចធ្វើទៅបាន នឹងមានការចេញលិខិតព្រមានជាលាយលក្ខណ៍អក្សរ មុននឹងចេញលិខិតមិនឲ្យចូលសាលារៀន ដោយជូនដំណឹងមាតាបិតា/អាណាព្យាបាលអំពីអាកប្បកិរិយាដែលមិនទាន់សមនឹងការមិនឲ្យចូលសាលារៀន តែអាចនឹងត្រូវគេមិនឲ្យចូលនៅពេលអនាគតបើមានអាកប្បកិរិយានោះម្តងទៀត។

ក្នុងកាលៈទេសៈដែលអាកប្បកិរិយារំខាន ឬហិង្សាខ្លាំងពេក វានឹងសមស្របនឹងការមិនឲ្យចូលសាលារៀនជាបន្ទាន់។ ក្នុងរយៈពេលនៃការមិនឲ្យចូលសាលារៀន មាតាបិតា/អាណាព្យាបាលដែលគេមិនឲ្យចូលសាលារៀន នឹងមិនអាចចូលក្នុងបរិវេណសាលារៀនដោយគ្មានការណាត់ជួបដែលអនុម័តដោយថ្នាក់ដឹកនាំសាលារៀនឡើយ។ តាមឆន្ទានុសិទ្ធិរបស់ខ្លួន សាលារៀនអាចជួបជាមួយមាតាបិតាដែលគេមិនឲ្យចូលសាលារៀនតាមអនឡាញ ជាជាងអនុញ្ញាតឱ្យមាតាបិតាចូលទីធ្លាសាលារៀនតាមរយៈការណាត់ជួប។ ពិធីការចេញលិខិតមិនឲ្យចូលសាលារៀនពេញលេញ គឺមាននៅលើគេហទំព័រ សិទ្ធិ និងទំនួលខុសត្រូវ របស់សិស្ស ។

# វត្តមានសិស្ស

ការស្រាវជ្រាវបង្ហាញថា វត្តមាន គឺជាកត្តាសំខាន់បំផុតចំពោះលទ្ធផលសិក្សារបស់សិស្ស។ សិស្សដែលចូលរៀនទាន់ពេល រៀងរាល់ថ្ងៃ ច្រើនតែទំនងជា៖

- ទទួលបានលទ្ធផលត្រឹមកម្រិតថ្នាក់ ឬលើសកម្រិតថ្នាក់សម្រាប់ការអាន និង គណិតវិទ្យា
- កសាងទំនាក់ទំនងដែលជួយគាំទ្រដល់សុខុមាលភាពផ្នែកអារម្មណ៍ និងសង្គមរបស់ពួកគេ
- និង បញ្ចប់ការសិក្សាពីវិទ្យាល័យដោយជោគជ័យ ទាន់ពេលវេលាជាង។

### ការចូលរៀន/វត្តមានជាកំហិត

ក្រោមច្បាប់រដ្ឋ Pennsylvania សិស្សទាំងអស់ដែលមានអាយុចន្លោះពីប្រាំមួយ (6) ឆ្នាំដល់ដប់ប្រាំបី (18) ឆ្នាំត្រូវតែចូលរៀនរាល់ថ្ងៃ។ នៅពេលដែលសិស្សម្នាក់បានចុះឈ្មោះចូលរៀនរួចហើយ នេះរាប់បញ្ចូលទាំងសិស្សអាយុប្រាំ (5) ឆ្នាំនៅថ្នាក់មត្តេយ្យ ពួកគេត្រូវស្ថិតក្រោមច្បាប់ចូលរៀនជាកំហិតរហូតដល់សិស្សមានអាយុដប់ប្រាំបី (18) ឆ្នាំ។ មាតាបិតា/អាណាព្យាបាលដែលចុះឈ្មោះកូនរបស់ពួកគេនៅថ្នាក់មត្តេយ្យអាចដកកូនរបស់ពួកគេចេញពីសាលារៀនជាផ្លូវការមុនពេលឈានដល់អាយុចូលរៀនជាកំហិត (ប្រាំមួយឆ្នាំ) នៅពេលនោះសិស្សលែងស្ថិតនៅក្រោមច្បាប់សាលាជាកំហិតរហូតដល់ពួកគេមានអាយុប្រាំមួយ (6) ឆ្នាំ។

វត្តមានគឺជាការតម្រូវសម្រាប់សិស្សទាំងអស់ក្នុងអំឡុងពេល និងម៉ោងដែលសាលាបង្រៀន លើកលែងតែបុគ្គលិកមណ្ឌលសិក្សាធិការ ដែលមានការអនុញ្ញាតអាចផ្តល់ច្បាប់ឲ្យសិស្សអវត្តមានបណ្តោះអាសន្នបានដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ គោលនយោបាយគណៈកម្មការ និងគោលការណ៍ណែនាំសម្រាប់អវត្តមាន និងការគេចសាលា។

សិស្សម្នាក់ត្រូវបានចាត់ទុកថាចូលរៀន បើគាត់មានវត្តមាននៅកន្លែងណាមួយដែលអាជ្ញាធរគណៈកម្មការកំពុងប្រជុំជាមួយសាលា ប្រសិនបើទទួលសេវាកម្មការបង្ហាត់បង្រៀន ឬសេវាសុខភាព ឬព្យាបាល ដែលគេអនុម័ត បើចូលរួមកម្មវិធីអប់រំពីអាជីព កម្មវិធីធ្វើការក្នុងពេលសិក្សា ឬកម្មវិធីសិក្សាឯករាជ្យដែលមានការត្រួតពិនិត្យត្រឹមត្រូវដែលគេអនុម័ត បើទទួលការបង្រៀននៅតាមផ្ទះដែលគេអនុម័ត ឬបើសិស្សត្រូវបានដាក់ឱ្យរៀននៅផ្ទះ។

មាតាបិតា/អាណាព្យាបាលត្រូវបានរំពឹងថានឹង៖

- ធានាថាសិស្សដែលមានអាយុចន្លោះប្រាំមួយ (6) ឆ្នាំ និងដប់ប្រាំបី (18) ឆ្នាំបានចុះឈ្មោះចូលរៀន និងចូលរៀនបានទៀងទាត់ ទាន់ពេល និងចូលរៀនពេញមួយថ្ងៃ។
- ផ្តល់ឱ្យសាលារៀននូវព័ត៌មានទំនាក់ទំនងបច្ចុប្បន្ន (អាសយដ្ឋាន ទូរសព្ទ អ៊ីមែល) នៅដើមឆ្នាំសិក្សានីមួយៗ ហើយធ្វើបច្ចុប្បន្នភាពព័ត៌មានជាមួយសាលារៀននៅពេលណាមានការផ្លាស់ប្តូរ។
- រៀបចំកាលវិភាគណាត់ជួប និងវិស្សមកាលគ្រួសារនៅក្រៅម៉ោងសិក្សា នៅពេលណាដែលអាចធ្វើទៅបាន។
- ធានាថាសិស្សទទួលបានការចាក់ថ្នាំបង្ការ និងការពិនិត្យសុខភាពដែលចាំបាច់សម្រាប់សិស្ស។
- ផ្តល់កំណត់សម្គាល់ជាលាយលក្ខណ៍អក្សរនៅរាល់ពេលអវត្តមាន មកដល់យឺត និងចេញមុនម៉ោង យោងតាមគោលនយោបាយ។
- ចូលរួមក្នុងកិច្ចប្រជុំលើកកម្ពស់វត្តមានសិស្សចូលរៀន ដើម្បីលើកកម្ពស់វត្តមានប្រចាំថ្ងៃរបស់សិស្ស នៅពេលចាំបាច់។

### អវត្តមានមានច្បាប់/អវត្តមានតាមច្បាប់

អវត្តមានមានច្បាប់ គឺនៅពេលសិស្សអវត្តមានពីសាលារៀនដោយសារហេតុផលដែលកំណត់ដោយមណ្ឌលសិក្សាធិការថាស្របច្បាប់ យកជាការបាន និង សមហេតុផល។ លក្ខខណ្ឌ ឬស្ថានភាពខាងក្រោមនេះ បង្កើតបានជាមូលហេតុសមហេតុផលសម្រាប់ការអវត្តមានពីសាលារៀន ដូចបានចែងនៅក្នុង គោលនយោបាយវត្តមានលេខ 204 របស់មណ្ឌលសិក្សាធិការ។ ករណីទាំងនេះមួយចំនួនមានលក្ខខណ្ឌផ្ទាល់ខ្លួនដែលត្រូវបំពេញឱ្យបានដើម្បីទទួលបានអវត្តមានដោយមានច្បាប់។

- ការទទួលការថែទាំសុខភាពបែបជំនាញ ឬសេវាកម្មព្យាបាលដែលផ្តល់ដោយពេទ្យជំនាញមានអាជ្ញាបណ្ណ។
  - ដោយផ្អែកលើសំណើជាលាយលក្ខណ៍អក្សរពីមាតាបិតា/អាណាព្យាបាល សិស្សអាចទទួលបានច្បាប់ឈប់ក្នុងអំឡុងម៉ោងសិក្សាចំពោះគោលបំណងទៅទទួលការថែទាំសុខភាពបែបជំនាញ ឬសេវាកម្មព្យាបាល តែក្នុងករណីបំពេញតាមលក្ខខណ្ឌតម្រូវខាងក្រោមនេះ៖
    - សេវាកម្មព្យាបាល ឬសេវាកម្មសុខភាព ត្រូវបានផ្តល់ដោយពេទ្យជំនាញមានអាជ្ញាបណ្ណ។
    - មិនអាចឱ្យសិស្សទទួលសេវាកម្មនេះនៅក្រៅម៉ោងសិក្សាបានទេ។
    - ពេលវេលានៃការអវត្តមានពីសាលារៀនជាចាំបាច់នេះ ប៉ះពាល់តិចតួចបំផុតជាមួយនឹងកម្មវិធីសិក្សាជាប្រចាំរបស់សិស្ស។
- ជំងឺ មានដូចជា ប្រសិនបើបុគ្គលិកមណ្ឌលសិក្សាធិការដែលបានជ្រើសតាំង បានឱ្យសិស្សចេញក្នុងអំឡុងម៉ោងសិក្សា ដោយសារហេតុផលទាក់ទងនឹងសុខភាព
- ចត្តាឡីស័ក
- ការស្តារសុខភាពពីគ្រោះថ្នាក់
- តម្រូវឱ្យបង្ហាញខ្លួននៅតុលាការ
- មរណភាពក្នុងគ្រួសារ
- ដំណើរកម្សាន្ត/ទេសចរណ៍អប់រំ បើបំពេញតាមលក្ខខណ្ឌខាងក្រោមនេះ៖
  - បុគ្គលក្នុងទំនាក់ទំនងបែបមាតាបិតា ដាក់ផ្ញើឯកសារដែលទាមទារឱ្យមានការលើកលែងមុនពេលអវត្តមាន ក្នុងរយៈពេលដែលសមស្រប។
  - នាយកសាលា ឬប្រធាននាយកអនុញ្ញាតឱ្យសិស្សចូលរួម។
  - មនុស្សពេញវ័យដែលដឹកនាំ និងមើលការខុសត្រូវដំណើរកម្សាន្ត ឬទេសចរណ៍ អាចទទួលយកបានចំពោះបុគ្គលក្នុងទំនាក់ទំនងបែបមាតាបិតា។
- ទេសចរណ៍នៅមហាវិទ្យាល័យ ទេសចរណ៍នៅសាលាពាណិជ្ជកម្ម ទេសចរណ៍កម្មវិធីបណ្តុះបណ្តាលមុខរបរនិងបច្ចេកទេស ទេសចរណ៍នៅមហាវិទ្យាល័យសហគមន៍ ឬទេសចរណ៍នៅសាលាផ្សេងទៀតដែលមិនមែនជាមណ្ឌលសិក្សាធិការ ដោយមានការយល់ព្រមជាមុន។
  - មណ្ឌលសិក្សាធិការអាចនឹងកម្រិតចំនួន និងរយៈពេលនៃដំណើរកម្សាន្ត ឬទេសចរណ៍អប់រំដែលមិនឧបត្ថម្ភដោយសាលារៀន ចំពោះអវត្តមានដែលគេអាចនឹងផ្តល់ច្បាប់ឈប់ដល់សិស្សក្នុងអំឡុងឆ្នាំសិក្សា។
- ការប្រារព្ធពិធីបុណ្យសាសនាដែលប្រតិបត្តិដោយក្រុមសាសនាពិតប្រាកដ ដោ យផ្អែកលើសំណើជាលាយលក្សណ៍អក្សរជាមុនពីបុគ្គលក្នុងទំនាក់ទំនងបែបមាតាបិតា។
- ការផ្អាកមិនឲ្យចូលសាលារៀន
- ការសង្គ្រោះបន្ទាន់ក្នុងគ្រួសារ (ព្រឹត្តិការណ៍ធ្ងន់ធ្ងរដែលនឹកស្មានមិនដល់ ដែលហួសពីការគ្រប់គ្រងរបស់គ្រួសារសិស្ស)
  - តម្រូវឱ្យមានកំណត់សម្គាល់ពីមាតាបិតាដែលពន្យល់ពីការសង្គ្រោះបន្ទាន់ ក្នុងរយៈពេល 3 ថ្ងៃសិក្សាចាប់ពីពេលសិស្សចូលរៀនវិញ។ បុគ្គលិកសាលារៀននឹងវាយតម្លៃថា តើស្ថានភាពនោះបង្កជាស្ថានភាពសង្គ្រោះបន្ទាន់ក្នុងគ្រួសារឬទេ។

### ការលើកលែងបណ្តោះអាសន្ន

សិស្សខាងក្រោមនេះអាចនឹងទទួលបានច្បាប់ឈប់បណ្តោះអាសន្នដោយមិនចាំបាច់មានវត្តមាននៅមណ្ឌលសិក្សាធិការ៖

- ក្នុងគោលបំណងទទួលការណែនាំបង្រៀនក្នុងផ្នែកដែលមិនមាននៅក្នុងកម្មវិធីសិក្សារបស់មណ្ឌលសិក្សាធិការ ដោយមានលក្ខខណ្ឌតម្រូវមួយចំនួន។
- សិស្សដែលចូលរួមក្នុងកម្មវិធីបង្រៀនខាងសាសនា ដោយមានលក្ខខណ្ឌមួយចំនួន។
- សិស្សដល់អាយុចូលរៀនតែមិនអាចចូលរៀនបានដោយផ្អែកលើការណែនាំរបស់គ្រូពេទ្យនៃសាលារៀន និងគ្រូពេទ្យជំងឺផ្លូវចិត្ត ឬចិត្តវិទូនៃសាលារៀន ឬទាំងពីរ ហើយដោយមានការយល់ព្រមពីលេខាធិការអប់រំនៃក្រសួងអប់រំនៃរដ្ឋ Pennsylvania។

### អវត្តមានអត់ច្បាប់/គ្មានច្បាប់

អវត្តមានត្រូវបានចាត់ទុកថា "អត់ច្បាប់" ឬ “គ្មានច្បាប់" នៅពេលដែលកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរពីមាតាបិតា/អាណាព្យាបាល អ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាបណ្ណ តុលាការ ឬឯកសារសុខុមាលភាពកុមារមិនបានដាក់ផ្ញើជូនសាលារៀន ពេលសិស្សត្រលប់ចូលរៀនវិញ (ដោយយោងតាមពិធីការអំពីកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ) ឬនៅពេលដែលហេតុផលនៅក្នុងកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលផ្តល់ដោយមាតាបិតា/អាណាព្យាបាលត្រូវបានសាលារៀនចាត់ទុកថា មិនបានការ និងមិនបំពេញតាមលក្ខខណ្ឌ ឬស្ថានភាពដែលមានចែងក្នុងគោលនយោបាយវត្តមានលេខ 204 របស់មណ្ឌលសិក្សាធិការ។ ឧទាហរណ៍អំពីការដោះសាមិនបានការ រួមមាន (ដោយមិនកំណត់ត្រឹមតែ)៖ ការមើលថែទារក ការភ្ញាក់ពីដេកយឺត សមាជិកគ្រួសារមានជំងឺ និងវិស្សមកាលគ្រួសារ។

## សេចក្តីជូនដំណឹងរបស់មាតាបិតាអំពីអវត្តមាន (កំណត់សម្គាល់ជាលាយលក្ខណ៍អក្សរ)

- គោលនយោបាយវត្តមានរបស់មណ្ឌលសិក្សាធិការតម្រូវឱ្យមានកំណត់សម្គាល់សុំច្បាប់ឈប់ដែលពន្យល់ពីការអវត្តមាន។
    - មាតាបិតា/អាណាព្យាបាលគួរទាក់ទងទៅសាលារៀនដើម្បីបញ្ជាក់ផ្ទៀងផ្ទាត់ពីវិធីដែលអាចដាក់ផ្ញើកំណត់សម្គាល់សុំច្បាប់ឈប់។
    - គួរប្រគល់កំណត់សម្គាល់សុំច្បាប់ឈប់ជូនសាលារៀនក្នុងពេលបី (3) ថ្ងៃពីពេលសិស្សត្រលប់ចូលរៀនវិញ។ បើមិនបានដាក់ផ្ញើកំណត់សម្គាល់ជូនសាលារៀននៅក្នុងរយៈពេលដែលបានតម្រូវទេ នោះថ្ងៃអវត្តមានអាចនឹងមិនមានច្បាប់ទេ។
    - កំណត់សម្គាល់សុំច្បាប់ឈប់ត្រូវតែមានឈ្មោះសិស្ស ថ្ងៃអវត្តមាន និងលេខទូរសព្ទដែលប្រើការបាន ឬមធ្យោបាយទំនាក់ទំនងផ្សេងទៀតសម្រាប់គោលបំណងផ្ទៀងផ្ទាត់។
- អវត្តមានណាដែលមានរយៈពេលចាប់ពីបី (3) ថ្ងៃជាប់គ្នាឡើងទៅដោយសារមានជំងឺ នឹងតម្រូវឱ្យមានកំណត់សម្គាល់សុំច្បាប់ឈប់ជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាបណ្ណ។ កំណត់សម្គាល់សុំច្បាប់ឈប់ពីអ្នកផ្តល់សេវាថែទាំសុខភាពក៏អាចដាក់ផ្ញើជំនួសឱ្យកំណត់សម្គាល់របស់មាតាបិតាបានផងដែរសម្រាប់រាល់អវត្តមាន។
- ចំពោះអវត្តមានទាំងអស់ និងអវត្តមានដែលសរុបតិចជាងបី (3) ថ្ងៃជាប់គ្នា មាតាបិតាអាចដាក់ផ្ញើកំណត់សម្គាល់សុំច្បាប់ឈប់ដោយប្រាប់ពីមូលហេតុនៃអវត្តមាន។
- នៅពេលសិស្សអវត្តមានដោយសារជំងឺ ដែលត្រូវបានឲ្យច្បាប់ឈប់ដោយមានកំណត់សម្គាល់របស់មាតាបិតា ដែលមានចំនួនប្រាំបី (8) ថ្ងៃ (ជាសរុប) នោះអវត្តមានបន្តបន្ទាប់ទៀត នឹងតម្រូវឱ្យមានកំណត់សម្គាល់សុំច្បាប់ឈប់ជាលាយលក្ខណ៍អក្សរពីអ្នកផ្តល់សេវាថែទាំសុខភាពដែលមានអាជ្ញាបណ្ណ។
- ការដាក់ផ្ញើកំណត់សម្គាល់មិនធានាការលើកលែងអវត្តមានដោយស្វ័យប្រវត្តិនោះទេ ហើយត្រូវស្ថិតក្រោមការត្រួតពិនិត្យពីសាលារៀនដើម្បីកំណត់សុពលភាពនៃកំណត់សម្គាល់ដែលបានដាក់ផ្ញើ។

## ការឆ្លើយតបនឹងការមិនចូលរៀន និងការគេចសាលា

ការគេចសាលាមានន័យថាអវត្តមានដោយគ្មានច្បាប់ចាប់ពីបី (3) ដងឡើងទៅក្នុងអំឡុងពេលឆ្នាំសិក្សាបច្ចុប្បន្ន ចំពោះសិស្សដែលស្ថិតក្រោមការចូលរៀនជាកំហិត។ សិស្សដែលអវត្តមានដោយគ្មានច្បាប់ចាប់ពីប្រាំមួយ (6) ដង ឡើងទៅត្រូវបានចាត់ទុកថាគេចសាលាជាទម្លាប់។ សិស្សដែលអវត្តមានដោយគ្មានច្បាប់ចាប់ពីដប់ (10) ដងឡើងទៅ ត្រូវបានចាត់ទុកថាគេចសាលារ៉ាំរ៉ៃ។ ចំពោះអវត្តមាននីមួយៗដែលបានកត់ត្រា មាតាបិតា/អាណាព្យាបាលទទួលសេចក្តីជូនដំណឹងតាមទូរសព្ទ អ៊ីមែល ឬសារជាអក្សរ។

<u>សេចក្តីជូនដំណឹងអំពីការគេចសាលា</u>

នៅពេលសិស្សដែលមានអាយុចូលរៀនជាកំហិត អវត្តមានរយៈពេលបី (3) ថ្ងៃ (ជាប់គ្នា/មិនជាប់គ្នា) ក្នុងអំឡុងឆ្នាំសិក្សាបច្ចុប្បន្ន ដោយគ្មានច្បាប់ត្រឹមត្រូវ នោះបុគ្គលិកមណ្ឌលសិក្សាធិការនឹងផ្តល់សេចក្តីជូនដំណឹងដល់មាតាបិតា/អាណាព្យាបាលក្នុងពេលដប់ (10) ថ្ងៃសិក្សាគិតចាប់ពីថ្ងៃអវត្តមានទីបីដែលអត់មានច្បាប់របស់សិស្ស។

<u>កិច្ចប្រជុំកែលម្អវត្តមានសិស្សចូលរៀន</u>

បើសិស្សបន្តបង្កើនអវត្តមានដែលអត់មានច្បាប់បន្ថែមទៀតបន្ទាប់ពីបានចេញសេចក្តីជូនដំណឹងនេះ នោះនឹងមានការអញ្ជើញមាតាបិតា/អាណាព្យាបាល និងសិស្សឱ្យចូលរួមកិច្ចប្រជុំកែលម្អវត្តមានសិស្សចូលរៀន (SAIC) ដែលនឹងមានការបង្កើតផែនការកែលម្អវត្តមានសិស្សចូលរៀន (SAIP) ដើម្បីពិភាក្សាអំពីអវត្តមានរបស់សិស្ស កំណត់ឧបសគ្គ និងអភិវឌ្ឍយុទ្ធសាស្ត្រប្រកបដោយអត្ថន័យ ក្នុងកិច្ចខិតខំកែលម្អវត្តមានដោយមាន ឬគ្មានសេវាកម្មបន្ថែម។ ត្រូវតែមានការអញ្ជើញមាតាបិតា/អាណាព្យាបាល និងសិស្ស ឱ្យចូលរួមក្នុងកិច្ចប្រជុំនេះជាមុន។ ទាំងសិស្ស និងមាតាបិតា/អាណាព្យាបាល មិនចាំបាច់ចូលរួមក៏បាន ទោះបីជាមានការចង់ឱ្យចូលរួមយ៉ាងខ្លាំងក៏ដោយ។ SAIC នៅតែប្រារព្ធឡើង ទោះបីជាមាតាបិតា/អាណាព្យាបាលបដិសេធមិនចូលរួម ឬខកខានមិនបានចូលរួមក្នុងកិច្ចប្រជុំដែលបានគ្រោងទុកនេះក៏ដោយ។

<u>តុលាការផ្នែកគេចសាលាប្រចាំតំបន់</u>

បើវត្តមានរបស់សិស្សមិនបានប្រសើរឡើង ក្រោយពេលអនុវត្ត និងតាមដានវឌ្ឍនភាព SAIP ហើយសិស្សបានកើនអវត្តមានដោយគ្មានច្បាប់ចាប់ពីដប់ (10) ដងឡើងទៅ នោះអាចនឹងមានការបញ្ជូន និងកំណត់ពេលឱ្យសិស្សចូលសវនាការរបស់តុលាការផ្នែកគេចសាលា ដើម្បីបង្ការ ដោះស្រាយ និងកាត់បន្ថយអាកប្បកិរិយាគេចសាលារ៉ាំរ៉ៃ។ គ្រួសារត្រូវបានជូនដំណឹងអំពីសវនាការតុលាការផ្នែកគេចសាលាជាមុនពីតុលាការគ្រួសារ។

<u>តុលាការគ្រួសារ</u>

បើវត្តមានរបស់សិស្សមិនបានប្រសើរឡើងនៅកម្រិតតុលាការផ្នែកគេចសាលាប្រចាំតំបន់ទេ គេអាចនឹងបញ្ជូនរឿងក្តីនេះទៅតុលាការគ្រួសារសម្រាប់សេវាកម្មដែលខ្លាំងជាងនេះ ដែលចៅក្រមមានសិទ្ធិអំណាចក្នុងការវិនិច្ឆ័យសិស្សដែលនៅក្នុងបន្ទុក និងប្រគល់រឿងក្តីទៅក្រសួងសេវាមនុស្សសម្រាប់សេវាកម្មដែលកាន់តែខ្លាំង។

<u>សិស្សដែលមានអាយុចូលរៀនមិនកំហិត (អាយុ 18 ឆ្នាំឡើងទៅ)</u>

សិស្សដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ គឺហួសអាយុចូលរៀនជាកំហិត។ បើសិនជាសិស្សមានអាយុចូលរៀនមិនកំហិត អវត្តមានដោយគ្មានច្បាប់រយៈពេលច្រើនថ្ងៃពេក បុគ្គលិកសាលារៀនអាចទាក់ទងទៅគ្រួសារដើម្បីផ្តល់ជំនួយ និងជូនដំណឹងទៅពួកគេអំពីលទ្ធភាពដែលសិស្សអាចត្រូវបានដកចេញពីបញ្ជីឈ្មោះដោយសារការមិនចូលរៀន។

សម្រាប់ព័ត៌មានបន្ថែមអំពីវត្តមាន រួមទាំងធនធាននានា សូមចូលទៅកាន់គេហទំព័រ philasd.org/attendtoday.

# បទបញ្ជាផ្ទៃក្នុងអំពីការស្លៀកពាក់

សិស្សមានសិទ្ធិស្លៀកពាក់តាមរបៀបដែលអបអរនូវអត្តសញ្ញាណពូជសាសន៍ វប្បធម៌ សាសនា និងយេនឌ័ររបស់ខ្លួន ឆ្លុះបញ្ចាំងពីការបង្ហាញលក្ខណៈភេទរបស់ខ្លួន (រួមទាំងអព្យាក្រឹតយេនឌ័រ) ហើយអនុញ្ញាតឱ្យសិស្សផ្តោតលើការអភិវឌ្ឍផ្នែកការសិក្សា សង្គម និងផ្លូវចិត្តរបស់ខ្លួន។ សិស្សត្រូវបានរំពឹងថានឹងធ្វើតាមបទបញ្ជាផ្ទៃក្នុងអំពីការស្លៀកពាក់របស់សាលា ដើម្បីកុំឱ្យរូបរាងរបស់ពួកគេបង្កគ្រោះថ្នាក់ដល់សុខភាព ឬសុវត្ថិភាព។ ដោយសហការជាមួយសហគមន៍សាលារៀនរបស់ខ្លួន ថ្នាក់ដឹកនាំសាលាត្រូវតែកំណត់ថាតើគោលនយោបាយស្លៀកពាក់របស់សាលានឹងជាគោលនយោបាយអ្វី ហើយបន្ទាប់មកផ្សព្វផ្សាយការសម្រេចចិត្តនោះមុននឹងចាប់ផ្តើមឆ្នាំសិក្សា។

គោលនយោបាយស្លៀកពាក់របស់សាលាទាំងអស់ត្រូវគោរពតាមគោលការណ៍ណែនាំរបស់មណ្ឌលសិក្សាធិការដូចខាងក្រោម៖

- សិស្សមានសិទ្ធិលេងម៉ូតសក់ការពារដូចជាសក់ក្រង សក់ក្រងបែបអាហ្វ្រិក សក់បួងឡើង សក់ឡើងប៉ោងបែបអាហ្វ្រិក សក់កណ្តាញ់ សក់ពាក់ រួមទាំងម៉ូតដែលមានគ្រឿងលម្អដូចជាបូរពាក់សក់ ក្រមារុំក្បាល មួកកាតិប ដង្កៀបសក់ ឬអង្កាំ។ សិស្សនឹងមិនត្រូវបានរើសអើងដោយសារប្រភេទសក់របស់ពួកគេឡើយ។ ការរើសអើងដោយសារម៉ូតសក់ការពារ និង/ឬប្រភេទសក់គឺជាការរើសអើងជាតិសាសន៍ខុសច្បាប់។
- សិស្សមានសិទ្ធិស្លៀកពាក់ស្របតាមអត្តសញ្ញាណយេនឌ័រ និង/ឬការបង្ហាញលក្ខណៈយេនឌ័រដែលបានបញ្ជាក់របស់ពួកគេ (រួមទាំងអព្យាក្រឹតភាពយេនឌ័រ) នៅក្នុងដែនកំណត់នៃបទបញ្ជាផ្ទៃក្នុងអំពីការស្លៀកពាក់របស់សាលា។
- សិស្សមានសិទ្ធិស្លៀកសម្លៀកបំពាក់សាសនាស្របតាមទំនៀមទម្លាប់សាសនារបស់ពួកគេ ដែលមិនអាចដាក់កម្រិត ឬហាមឃាត់ឡើយ។
- ស្បៃមុខ ឬស្បៃមុខផ្សេងទៀតដែលមិនមែនជាសាសនា (មិនរួមបញ្ចូលម៉ាស់វេជ្ជសាស្ត្រ) មិនត្រូវបានអនុញ្ញាតដោយហេតុផលណាមួយឡើយ។
- គ្មានសិស្សណាម្នាក់នៅក្នុង School District of Philadelphia អាចត្រូវបានដកចេញពីបរិយាកាសក្នុងថ្នាក់រៀន រួមទាំងត្រូវបានបដិសេធមិនឲ្យចូលសាលា ព្យួរ ឬបណ្តេញចេញដោយសារមិនអនុវត្តតាមបទបញ្ជាផ្ទៃក្នុងអំពីការស្លៀកពាក់ឡើយ។

សិស្សដែលមិនមានលទ្ធភាពទទួលបានធនធានដើម្បីប្រកាន់ខ្ជាប់នូវបទបញ្ជាផ្ទៃក្នុងអំពីការស្លៀកពាក់របស់សាលាគួរពិភាក្សាអំពីករណីទាំងនេះជាមួយទីប្រឹក្សាសាលារបស់ពួកគេ។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងបទបញ្ជាផ្ទៃក្នុងអំពីការស្លៀកពាក់របស់សាលា សូមមើលសៀវភៅណែនាំរបស់សាលារៀន។

# ការបង្រៀនតាមអនឡាញ និងឧបករណ៍អេឡិចត្រូនិក

សិស្សទាំងអស់ត្រូវបានរំពឹងថានឹងទៅសាលារៀនដោយផ្ទាល់ លុះត្រាតែមានការបិទសាលាដែលមានការអនុម័ត (ឧ.ជំងឺ COVID-19 សារធាតុអាបែស្តូ អាកាសធាតុមិនល្អ) ឬសិស្សត្រូវបាន អនុម័តសម្រាប់សេវាកម្មបង្រៀន នៅផ្ទះ ដោយសារហេតុផលវេជ្ជសាស្ត្របន្ទាន់។ បើមិនដូច្នេះទេ សិស្សមិនត្រូវបានអនុញ្ញាតឱ្យស្នាក់នៅផ្ទះមិនទៅសាលារៀន និងបំពេញកិច្ចការតាមអនឡាញ តាមរយៈ google classroom ឬកម្មវិធីផ្សេងទៀត ដែលជាមធ្យោបាយទទួលបានការអប់រំនោះទេ។

គ្រួសារដែលចាប់អារម្មណ៍លើការបង្រៀនពេញម៉ោងតាមអនឡាញអាចដាក់ពាក្យទៅសាលា Philadelphia Virtual Academy (PVA) ជាសាលាបង្រៀនថ្នាក់មត្តេយ្យដល់ទី 12 តាមអនឡាញរបស់ School District of Philadelphia បាន។ សិស្សនៅតែអាចទទួលបានការគាំទ្រដោយផ្ទាល់តាមរយៈមជ្ឈមណ្ឌលគាំទ្រការសិក្សាក៏ដូចជាសកម្មភាពក្រៅកម្មវិធីសិក្សាផងដែរ។ ទទួលយកពាក្យស្នើសុំតាមមូលដ្ឋានរំកិល។

### ការប្រើប្រាស់អ៊ីនធឺណិត និងបច្ចេកវិទ្យាដែលអាចទទួលយកបាន

បច្ចេកវិទ្យាគឺជាផ្នែកមួយដែលរីកចម្រើនឥតឈប់ឈរនៃការអប់រំ ហើយដូច្នេះ សិស្សអាចប្រើ Chromebooks និង ឧបករណ៍អេឡិចត្រូនិក/កម្មវិធីផ្សេងទៀតដែលផ្តល់ដោយគ្រូរបស់ពួកគេដើម្បីបំពេញកិច្ចការ។ មាតាបិតា/អាណាព្យាបាលត្រូវបានរំពឹងថានឹងពិនិត្យមើលការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយទំនួលខុសត្រូវ និងសុវត្ថិភាពជាមួយកូនរបស់ពួកគេ ដូចមានចែងនៅក្នុង គោលនយោបាយគណៈកម្មការសាលាលេខ 815។ គួរតែរំលឹកសិស្ស៖

- កុំឲ្យចែករំលែកពាក្យសម្ងាត់ ទីតាំង ឬព័ត៌មានផ្ទាល់ខ្លួនណាមួយនៅលើអ៊ីនធឺណិត។
- កុំបង្ហោះ/ចែករំលែកព័ត៌មានអំពីសមាជិកសហគមន៍ផ្សេងទៀតនៅលើឧបករណ៍របស់មណ្ឌលសិក្សាធិការ ឬឧបករណ៍ផ្ទាល់ខ្លួន។
- កុំឲ្យចូលមើលគេហទំព័រដែលបង្កគ្រោះថ្នាក់ ឬមិនសមរម្យសម្រាប់អនីតិជន។
- កុំឲ្យលួចចម្លង តែងតែអនុវត្តភាពត្រឹមត្រូវនៃការសិក្សា នៅពេលប្រើប្រាស់អ៊ីនធឺណិត ដើម្បីគាំទ្រដល់ការបញ្ចប់កិច្ចការ (ឧ. សេចក្តីដកស្រង់)។

ប្រសិនបើមាតាបិតា/អាណាព្យាបាលកំណត់បញ្ហាកង្វល់អំពីសន្តិសុខ និង/ឬសុវត្ថិភាពជាមួយឧបករណ៍ដែលសាលារបស់ពួកគេផ្តល់ជូន និង/ឬកម្មវិធីអប់រំ ពួកគេគួរតែជូនដំណឹងដល់ថ្នាក់ដឹកនាំសាលាជាបន្ទាន់។ ព័ត៌មានបន្ថែមអំពីសុវត្ថិភាពតាមអ៊ីនធឺណិតអាចរកបាននៅលើគេហទំព័រ ការិយាល័យបច្ចេកវិទ្យាអប់រំ។

### ការកាន់កាប់ឧបករណ៍អេឡិចត្រូនិករបស់សិស្ស

សិស្សមណ្ឌលសិក្សាធិការមិនអាចប្រើឧបករណ៍កុំព្យូទ័រផ្ទាល់ខ្លួន រួមទាំងសម្រាប់គោលបំណងអប់រំ ខណៈពេលដែលនៅក្នុងអគារមណ្ឌលសិក្សាធិការបានទេ ហើយគួរតែប្រើឧបករណ៍កុំព្យូទ័ររបស់មណ្ឌលសិក្សាធិការជំនួសវិញ។ អាចប្រើទូរសព្ទដៃ និងឧបករណ៍ប្រភេទអាចពាក់បានដោយអនុលោមតាមពិធីការជាក់លាក់របស់សាលា ដូចមានចែងនៅក្នុង គោលនយោបាយគណៈកម្មការសាលាលេខ 237។

សិស្សមិនគួរប្រើទូរសព្ទដៃ ឬឧបករណ៍ប្រភេទអាចពាក់បាននៅក្នុងថ្នាក់រៀនឡើយ លុះត្រាតែមានការអនុញ្ញាតពីបុគ្គលិកសាលា។ សាលានីមួយៗបង្កើតពិធីការផ្ទាល់ខ្លួនរបស់ពួកគេ ដែលកំណត់ការរំពឹងទុកថាសិស្សប្រើប្រាស់ទូរសព្ទដៃ និងឧបករណ៍ប្រភេទអាចពាក់បាន។ សាលាអាចបង្កើតពិធីការដែលកំណត់តំបន់នៅក្នុងសាលា និងម៉ោងនៃថ្ងៃដែលសិស្សប្រើប្រាស់ទូរសព្ទដៃ ឬឧបករណ៍ប្រភេទអាចពាក់បានត្រូវបានអនុញ្ញាត ក្នុងចំណោមច្បាប់ផ្សេងទៀតសម្រាប់សិស្សប្រើប្រាស់ទូរសព្ទ ឬឧបករណ៍ប្រភេទអាចពាក់បានក្នុងអំឡុងពេលម៉ោងសិក្សា។

ពិធីការស្តីពីឧបករណ៍អេឡិចត្រូនិកត្រូវបានរៀបរៀងឡើងដើម្បីបង្កើនសុវត្ថិភាពសិស្ស ការសិក្សា និងការចូលរួម។ ប្រសិនបើសិស្សមិនអាចប្រើឧបករណ៍ផ្ទាល់ខ្លួន ហើយត្រូវការទាក់ទងមាតាបិតា/អាណាព្យាបាលក្នុងករណីមានអាសន្ន ពួកគេគួរតែធ្វើសំណើនេះទៅកាន់បុគ្គលិកសាលា។

ចំពោះសំណួរ/កង្វល់បន្ថែម សូមទាក់ទងនាយកសាលារបស់អ្នក។

## សិទ្ធិរបស់សិស្ស និងអាណាព្យាបាល

មានការការពារមួយចំនួនសម្រាប់សិស្ស និងក្រុមគ្រួសារ ក៏ដូចជាធនធានដែលមានស្រាប់ដើម្បីគាំទ្រដល់សុវត្ថិភាព សុខុមាលភាព និងភាពជោគជ័យរបស់សិស្ស។

### សិស្សដែលជួបប្រទះបញ្ហាគ្មានផ្ទះសម្បែង

មណ្ឌលសិក្សាធិការប្រកាន់ខ្ជាប់នូវច្បាប់ McKinney-Vento ស្តីពីជំនួយជនគ្មានផ្ទះសម្បែង ដែលធានាការចុះឈ្មោះចូលរៀនភ្លាមៗ និងស្ថិរភាពនៃការអប់រំសម្រាប់សិស្សដែលជួបប្រទះបញ្ហាគ្មានផ្ទះសម្បែង។ បញ្ហាគ្មានផ្ទះសម្បែងត្រូវបានកំណត់ថាជាជនណាម្នាក់ដែលខ្វះកន្លែងស្នាក់នៅទៀងទាត់ និងគ្រប់គ្រាន់នៅពេលយប់។ នេះរាប់បញ្ចូលទាំងសិស្សដែលកំពុងរស់នៅក្នុងលំនៅឋានជាមួយមនុស្សផ្សេងទៀតដោយសារតែការបាត់បង់លំនៅឋាន ភាពលំបាកផ្នែកសេដ្ឋកិច្ច ឬហេតុផលស្រដៀងគ្នា (ដែលគេស្គាល់ថាជារស់នៅក្នុងបន្ទប់ជាមួយគ្នា ឬដេកនៅលើសាឡុងនៅផ្ទះអ្នកដទៃ) ការរស់នៅបណ្តោះអាសន្នក្នុងផ្ទះសំណាក់ ម៉ូតែល ឧទ្យាន ឬកន្លែងបោះជំរំ ការរស់នៅក្នុងកន្លែងសាធារណៈ ឬឯកជន ដែលមិនបានបង្កើតឡើងសម្រាប់ ឬជាធម្មតាប្រើជាកន្លែងដេកសម្រាប់មនុស្ស ការរស់នៅក្នុងរថយន្ត អគារដែលគេបោះបង់ចោល ឬលំនៅឋានខុសស្តង់ដា ឬស្ថានភាពស្រដៀងគ្នា និងជនភៀសខ្លួន ឬជនចំណាកស្រុក ប្រសិនបើពួកគេរស់នៅក្នុងស្ថានភាពដូចដែលបានពិពណ៌នាខាងលើ។

យុវជនអនាថាក៏ស្ថិតនៅក្រោមប្រភេទនេះផងដែរ ហើយអាចចាត់ទុក ជាយុវជនដែលមិនស្ថិតក្នុងការឃុំគ្រងរបស់មាតាបិតា ឬអាណាព្យាបាលស្របច្បាប់ និងយុវជនដែលរស់នៅដោយខ្លួនឯងក្នុងស្ថានភាពគ្មានផ្ទះសម្បែងណាមួយដែលបានពិពណ៌នាខាងលើ។ សិស្សស្ថិតក្រោមការថែទាំរបស់ទីភ្នាក់ងារកុមារ និងយុវជន (ប្រព័ន្ធចិញ្ចឹមថែទាំកុមារ) មិនត្រូវបានរាប់បញ្ចូលទេ លុះត្រាតែពួកគេបាត់បង់ទីលំនៅផងដែរ។ សិស្សដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពគ្មានផ្ទះសម្បែង ទោះបីជាមិនមាន អាណាព្យាបាលក៏ដោយ ក៏ត្រូវតែទទួលបានសិទ្ធិពេញលេញ និងស្មើភាពក្នុងការទទួលបានការអប់រំសាធារណៈសមស្រប និងជោគជ័យក្នុងកម្មវិធីអប់រំ។ ភាពអចិន្ត្រៃយ៍ និងភាពគ្រប់គ្រាន់នៃលក្ខខណ្ឌលំនៅឋាននឹងត្រូវបានយកមកពិចារណានៅពេលកំណត់ថាតើសិស្សមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែរឬទេ។

សិស្សទាំងនេះអាចចុះឈ្មោះចូលរៀន៖

- សាលាដែលសិស្សបានចូលរៀនពេលត្រូវបានផ្តល់កន្លែងស្នាក់នៅជាអចិន្ត្រៃយ៍ (សាលាដើម)។
- សាលាណាដែលសិស្សរស់នៅក្នុងតំបន់ភូមិសាស្ត្រជាប់គ្នា ដែលសិស្សកំពុងជួបបញ្ហាគ្មានផ្ទះសម្បែង កំពុងរស់នៅគឺមានសិទ្ធិចូលរៀន (សាលាថ្មីជាប់ព្រំប្រទល់គ្នា)។

យុវជនអនាថាដែលមានផែនការអប់រំបុគ្គល (IEP) ក៏អាចត្រូវមានអ្នកជំនួសមាតាបិតាដែលមណ្ឌលសិក្សាធិការបានតែងតាំងក្នុងរយៈពេល 30 ថ្ងៃ បើសិស្សមិនមាននរណាម្នាក់បំពេញតួនាទីនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងផ្នែក អប់រំសម្រាប់កុមារ និងយុវជនគ្មានផ្ទះសម្បែង (ECYEH) តាមវិធីខាងក្រោម៖ ទូរសព្ទ៖ 215-400-4830 (ជម្រើសទី 4) អ៊ីមែល៖ ecyeh@philasd.org; ទម្រង់បែបបទបញ្ជូនបន្តតាមអនឡាញរបស់ ECYEH។

## សិស្សស្ថិតក្រោមការចិញ្ចឹមថែទាំ
មណ្ឌលសិក្សាធិការប្រកាន់ខ្ជាប់នូវច្បាប់ស្តីពីភាពជោគជ័យរបស់សិស្សគ្រប់រូប (ESSA) ដើម្បីគាំទ្រដល់សិស្សស្ថិតក្រោមការចិញ្ចឹមថែទាំ។ សិស្សស្ថិតក្រោមការចិញ្ចឹមថែទាំនៅតែនៅក្នុងសាលាដើមរបស់ពួកគេ (សាលាដែលសិស្សត្រូវបានចុះឈ្មោះនៅពេលដាក់ឲ្យរៀន) លុះត្រាតែមានការសម្រេចចិត្តថា ការចូលសាលានោះមិនផ្តល់ឧត្តមប្រយោជន៍ដល់ពួកគេ។ បើសិស្សទើបចូលមណ្ឌលចិញ្ចឹមថែទាំ ឬជួបប្រទះការផ្លាស់ប្តូរសាលា កិច្ចប្រជុំអំពីសេចក្តីសម្រេចឧត្តមប្រយោជន៍ (BID) នឹងត្រូវធ្វើឡើងដើម្បីកំណត់ថាតើសិស្សគួរតែបន្តនៅក្នុងសាលាដើម ឬប្រសិនបើពួកគេគួរតែផ្លាស់ប្តូរទៅសាលាថ្មី។ ឪពុកម្តាយធម៌ និង/ឬបុគ្គលិកផ្នែកចិញ្ចឹមថែទាំកុមារមិនគួរធ្វើការផ្លាស់ប្តូរណាមួយចំពោះការចុះឈ្មោះចូលរៀនសម្រាប់សិស្សស្ថិតក្រោមការចិញ្ចឹមថែទាំដោយមិនមានកិច្ចប្រជុំ BID ដែលធ្វើឡើងលើកដំបូងនោះឡើយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងផ្នែកសេវាកម្មចិញ្ចឹមថែទាំកុមារតាមវិធីខាងក្រោម៖ ទូរសព្ទ៖ 215-400-4830 ឬ
អ៊ីមែល៖ fostercareservices@philasd.org.

## សិស្សកែភេទ និងយេនឌ័រមិនអនុលោមតាម
សិស្សប្តូរភេទ និងយេនឌ័រមិនអនុលោមតាមទទួលបានសិទ្ធិ និងការការពារមួយចំនួនក្រោម គោលនយោបាយគណៈកម្មការសាលាលេខ 252 រួមទាំង៖

- សិទ្ធិឯកជនភាព ហើយនេះរួមបញ្ចូលទាំងសិទ្ធិរក្សាអត្តសញ្ញាណអ្នកប្តូរភេទជាឯកជននៅសាលា។
- ខណៈដែលសិស្សមានសិទ្ធិ "បញ្ចេញ" បើពួកគេជ្រើសរើស បុគ្គលិកសាលាមិនគួរបញ្ចេញព័ត៌មានដែលអាចបង្ហាញពីអត្តសញ្ញាណប្តូរភេទ ឬអត្តសញ្ញាណយេនឌ័រមិនអនុលោមតាមរបស់សិស្សដល់អ្នកដទៃ រួមទាំងមាតាបិតា និងបុគ្គលិកសាលាផ្សេងទៀតទេ លុះត្រាតែសិស្សបានអនុញ្ញាតឱ្យបញ្ចេញព័ត៌មានបែបនេះ។
- សិស្សមានសិទ្ធិឲ្យគេហៅឈ្មោះ និងសព្វនាមដែលខ្លួនជ្រើសរើស។ មណ្ឌលសិក្សាធិការទទួលស្គាល់ថា លោកគ្រូអ្នកគ្រូ បុគ្គលិក និងសិស្សដទៃទៀតដែលបដិសេធម្តងហើយម្តងទៀតក្នុងការមិនគោរពឈ្មោះ និងសព្វនាមដែលសិស្សនោះបានជ្រើសរើស ត្រូវបានចាត់ទុកថាជាការរើសអើង ហើយអាកប្បកិរិយាបែបនេះបង្កើតឱ្យមានបរិយាកាសគ្រោះថ្នាក់ និងអរិភាព។
- សិទ្ធិដាក់បញ្ចូលនៅក្នុងក្រុមដែលត្រូវគ្នាទៅនឹងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ នេះរួមបញ្ចូលទាំងក្រុមអត្តពលិក និងកម្មវិធីពាក់ព័ន្ធ។
- សិទ្ធិមានសិទ្ធិចូលបន្ទប់ទឹក ឬបន្ទប់ផ្លាស់ប្តូរសម្លៀកបំពាក់ដែលត្រូវនឹងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។

លើសពីនេះ មណ្ឌលសិក្សាធិការបានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់សុវត្ថិភាព និងធានាបរិយាកាសសាលារៀនសម្រាប់សិស្សទាំងអស់ ប៉ុន្តែជាពិសេសបរិយាកាសដែលសិស្ស LGBTQ+ អាចធ្វើជាខ្លួនឯងនៅពេលចូលរៀនដូចគ្នានឹងសិស្សដទៃទៀតដែរ។ ការិយាល័យសិទ្ធិ និងទំនួលខុសត្រូវរបស់សិស្សប្តេជ្ញាបន្ថែមទៀតក្នុងការដោះស្រាយបញ្ហាអំពីភេទ លក្ខណៈភេទ និងការរើសអើងផ្អែកលើយេនឌ័រ និង/ឬពាក្យបណ្តឹងទាក់ទងនឹងការប្រមាថ និងការបៀតបៀនសិស្ស LGBTQ+ ដូចមានចែងខាងក្រោម (ទំព័រទី 13)។

សំណើសុំឈ្មោះ និង/ឬការផ្លាស់ប្តូរយេនឌ័រអាចធ្វើឡើងដោយបំពេញ ទម្រង់បែបបទអេឡិចត្រូនិក។ ទម្រង់បែបបទនេះអាចត្រូវបានបំពេញដោយសិស្ស ឬបុគ្គលិកតំណាងឱ្យពួកគេ។ សម្រាប់សំណួរទាក់ទងនឹងគោលនយោបាយគណៈកម្មការសាលាលេខ 252 សូមទាក់ទងមណ្ឌលសិក្សាធិការតាមអ៊ីមែល៖ policy252@philasd.org.

## ការប្រតិបត្តិសាសនា
មាតាបិតា/អាណាព្យាបាលអាចស្នើសុំច្បាប់ឱ្យសិស្សម្នាក់ឈប់ ដើម្បីចូលរួមការប្រតិបត្តិសាសនាដូចខាងក្រោម៖
- ថ្ងៃឈប់សម្រាកបុណ្យសាសនា សិស្សអាចត្រូវបានសាលាឲ្យឈប់ដោយមានច្បាប់សម្រាប់ថ្ងៃឈប់សម្រាកបុណ្យសាសនាដែលត្រូវបានប្រារព្ធដោយក្រុមសាសនាដែលបានទទួលស្គាល់។
- ការបង្រៀនសាសនា តាមការស្នើសុំ សិស្សអាចត្រូវបានសាលាឲ្យឈប់ដោយមានច្បាប់ ដើម្បីចូលរៀនថ្នាក់បង្រៀនសាសនា។
  - សំណើត្រូវកំណត់ និងពណ៌នាអំពីការបង្រៀន និងកាលបរិច្ឆេទ និងម៉ោងដែលសុំច្បាប់អវត្តមាន។
  - ការលើកលែងត្រូវតែកំណត់ត្រឹមសរុប 36 ម៉ោងក្នុងមួយឆ្នាំសិក្សា។
  - បន្ទាប់ពីអវត្តមាននីមួយៗ មាតាបិតា/អាណាព្យាបាលត្រូវផ្តល់លិខិតដែលបញ្ជាក់ថា សិស្សពិតជាបានចូលរៀនថ្នាក់បង្រៀនសាសនា និងកាលបរិច្ឆេទ និងម៉ោងដែលការចូលរៀនបែបនេះបានកើតឡើងមែន។
- ការអធិស្ឋានអំឡុងពេលម៉ោងសិក្សា សិស្សអាចនឹងត្រូវបានអនុញ្ញាតឱ្យចូលរួមធ្វើការអធិស្ឋាននៃសាសនាដែលទទួលស្គាល់ក្នុងអំឡុងពេលម៉ោងសិក្សានៅក្នុងអគារសិក្សា ទោះបីជាយ៉ាងណាក៏ដោយ ការអធិស្ឋានមិនគួរធ្វើឡើងក្នុងអំឡុងពេលបង្រៀន ដើម្បីកាត់បន្ថយជាអប្បបរមានូវការរំខានដល់ការសិក្សាណាមួយឡើយ។

## សំណើសុំការវាយតម្លៃការអប់រំពិសេស
សិស្សណាម្នាក់ដែលសង្ស័យថាមានពិការភាពត្រូវតែទទួលបានការវាយតម្លៃ ដើម្បីកំណត់សិទ្ធិទទួលបានរបស់សិស្សក្នុងការទទួលបានផែនការអប់រំបុគ្គល (IEP) ក្រោមច្បាប់ស្តីពីបុគ្គលដែលមានពិការភាព (IDEA)។ ថ្នាក់ដឹកនាំសាលា ឬមាតាបិតា/អាណាព្យាបាលអាចចាប់ផ្តើមដំណើរការនេះបាន។ មាតាបិតា/អាណាព្យាបាលគួរតែស្នើសុំការវាយតម្លៃជាលាយលក្ខណ៍អក្សរ ប៉ុន្តែសំណើនឹងត្រូវបានទទួលយកដោយផ្ទាល់មាត់។ នៅពេលដែលសំណើត្រូវបានធ្វើឡើង សាលាត្រូវឆ្លើយតបក្នុងរយៈពេលដប់ (10) ថ្ងៃប្រតិទិន។ សាលានឹងចេញ "លិខិតអនុញ្ញាតវាយតម្លៃ" (PTE) ឬសេចក្តីជូនដំណឹងអំពីការដាក់ការអប់រំដែលបានណែនាំ (NOREP) ដើម្បីពន្យល់ជាលាយលក្ខណ៍អក្សរអំពីមូលហេតុដែលសំណើសុំវាយតម្លៃត្រូវបានបដិសេធ។ បើចេញលិខិត PTE សាលាត្រូវតែព្យាយាមបី (3) ដងដើម្បីទទួលបានពាក្យយល់ព្រមដែលមានចុះហត្ថលេខា។ បើមិនទទួលបានពាក្យយល់ព្រមដែលមានចុះហត្ថលេខាទេ នោះសាលាមិនអាចបន្តការវាយតម្លៃបានឡើយ។ សម្រាប់សំណួរនានា សូមចូលទៅកាន់គេហទំព័រ ការិយាល័យអ្នកសិក្សាចម្រុះ ឬទាក់ទងអ្នកត្រួតពិនិត្យអនុលោមភាពនៃការអប់រំពិសេស (SPECM) របស់សាលា។

## ការស្នើសុំផែនការសេវាកម្ម 504
សិស្សដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្មអប់រំពិសេសក្រោមច្បាប់ IDEA អាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់ផែនការ 504 ក្រោមមាត្រាទី 504 នៃច្បាប់ស្តីពីការស្តារនីតិសម្បទា ដែលជាច្បាប់សិទ្ធិស៊ីវិលដែលការពារសិស្សពីការរើសអើងដោយផ្អែកលើពិការភាព។ ដើម្បីរកឃើញថាមានសិទ្ធិសម្រាប់ផែនការ 504 សិស្សត្រូវតែមានភាពចុះខ្សោយផ្លូវកាយ ឬផ្លូវចិត្តដែលដាក់កំហិតយ៉ាងច្រើនលើសមត្ថភាពសិក្សារបស់ពួកគេ។ មាតាបិតា/អាណាព្យាបាលអាចស្នើសុំផែនការ 504 ដោយទាក់ទងអ្នកប្រឹក្សាសាលា ឬថ្នាក់ដឹកនាំសាលាផ្សេងទៀត។ សំណើគួរតែធ្វើឡើងជាលាយលក្ខណ៍អក្សរ និងរួមបញ្ចូលកំណត់ត្រាវេជ្ជសាស្ត្រដែលពាក់ព័ន្ធ រួមជាមួយនឹងការណែនាំសម្រាប់សេវាកម្មជាក់លាក់ ឬការសម្របសម្រួលដែលសិស្សអាចត្រូវការ។ សម្រាប់សំណួរនានាទាក់ទងនឹងដំណើរការ 504 សូមទាក់ទងការិយាល័យបង្ការ និងអន្តរាគមន៍ដោយប្រើ ទម្រង់បែបបទសាកសួរ 504 ឬផ្ញើអ៊ីមែលទៅ 504information@philasd.org។

## ការលុបចោលកំណត់ត្រាសម្រាប់សិស្សដែលត្រូវបានបណ្តេញចេញ
សិស្សដែលត្រូវបានបណ្តេញចេញជាអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នដោយសំឡេងវិជ្ជមានភាគច្រើននៃគណៈកម្មការសាលា អាច <185>ដាក់ពាក្យសុំលុបចោលកំណត់ត្រានៃការបណ្តេញចេញក្រោម គោលនយោបាយគណៈកម្មការសាលាលេខ 233។ ការលុបចោលកំណត់ត្រាធ្វើឡើងតាមឆន្ទានុសិទ្ធិរបស់ប្រធាននាយក ឬអ្នកតំណាង ហើយមិនស្ថិតនៅក្រោមការត្រួតពិនិត្យឡើងវិញ ឬប្តឹងទៅគណៈកម្មការសាលា ឬតុលាការឡើយ។

## មាតាបិតា/អាណាព្យាបាល និងភ្ញៀវដែលមានការអនុញ្ញាត
គោលនយោបាយគណៈកម្មការសាលាលេខ 904 ចែងថា មាតាបិតា/អាណាព្យាបាលដែលមានពិការភាព ឬភ្ញៀវដែលមានការអនុញ្ញាត ដែលទាមទារការសម្របសម្រួលសមរម្យ ដើម្បីជួយមានវត្តមាន/ការចូលរួមរបស់ពួកគេនៅក្នុងកម្មវិធីសាលា គួរតែទាក់ទងអ្នករៀបចំគ្រប់គ្រងកម្មវិធី។ នេះត្រូវតែធ្វើឡើងយ៉ាងហោចណាស់បី (3) ថ្ងៃនៃថ្ងៃធ្វើការមុនកម្មវិធីដែលបានគ្រោងទុក ឬបី (3) ថ្ងៃបន្ទាប់ពីបានទទួលការជូនដំណឹងអំពីកម្មវិធីនេះ ណាមួយដែលសម្រេចបាននូវការជូនដំណឹងមុនគេបំផុតទៅកាន់មណ្ឌលសិក្សាធិការ។ សំណើគួរតែធ្វើឡើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ពីព្រោះការសម្របសម្រួលមួយចំនួនត្រូវការពេលវេលាបន្ថែមដើម្បីរៀបចំ/ចាត់ចែង។

## លទ្ធភាពទទួលបានភាសា
មាតាបិតា/អាណាព្យាបាលមានសិទ្ធិទទួលបានសារទំនាក់ទំនង និងព័ត៌មានពីមណ្ឌលសិក្សាធិការ និងសាលារបស់សិស្ស ជាភាសាដែលពួកគេចង់បាន។ ប្រសិនបើមាតាបិតា/អាណាព្យាបាលនិយាយ និង/ឬសរសេរភាសាផ្សេងក្រៅពីភាសាអង់គ្លេស អ្នកបកប្រែផ្ទាល់មាត់ត្រូវតែផ្តល់ជូនសម្រាប់ការហៅទូរសព្ទ និងការប្រជុំជាមួយបុគ្គលិកសាលា ហើយសារទំនាក់ទំនងជាលាយលក្ខណ៍អក្សរពីសាលាត្រូវតែបកប្រែទៅជាភាសាដែលពួកគេចង់បាន។ គ្រូបង្រៀន និងបុគ្គលិកសាលាគួរតែប្រើប្រាស់ធនធានជាច្រើនដើម្បីផ្តល់លទ្ធភាពទទួលបានភាសា ដូចជាលេខទូរសព្ទសម្រាប់ភាសា ជំនួយការប្រឹក្សាពីរភាសា និង ទម្រង់បែបបទស្នើសុំការបកប្រែ ដើម្បីចូលរួមជាមួយអ្នកសិក្សាភាសាអង់គ្លេសរបស់មណ្ឌលសិក្សាធិការ និងមាតាបិតា/អាណាព្យាបាលដែលចេះច្រើនភាសា។ សាលាត្រូវតែកត់ត្រាភាសាដែលមាតាបិតា/អាណាព្យាបាលចង់បាន ហើយផ្តល់ឱ្យពួកគេនូវព័ត៌មានអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានសេវាកម្មភាសា និងរបៀបចូលប្រើធនធានជាភាសាដែលពួកគេចង់បាន។ គ្រួសារអាចស្វែងយល់បន្ថែមអំពីជំនួយគាំទ្រពហុភាសារបស់មណ្ឌលសិក្សាធិការ ដាក់ពាក្យបណ្តឹងអំពីលទ្ធភាពទទួលបានភាសា និង/ឬផ្តល់មតិកែលម្អតាមរយៈទម្រង់បែបបទ google នៅលើគេហទំព័រ ការចូលរួមរបស់គ្រួសារ និងសហគមន៍។

## បណ្តឹងតវ៉ារបស់មាតាបិតា/អាណាព្យាបាល
ការិយាល័យសិទ្ធិ និងទំនួលខុសត្រូវរបស់សិស្សមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យសេចក្តីសម្រេចដែលធ្វើឡើងដោយសាលា និង/ឬបុគ្គលិកការិយាល័យកណ្តាល ដើម្បីកំណត់ថាតើការសម្រេចចិត្តនេះត្រូវបានធ្វើឡើងដោយអនុលោមតាមគោលនយោបាយ នីតិវិធី និងពិធីការរបស់មណ្ឌលសិក្សាធិការដែរឬអត់។

អាចប្តឹងតវ៉ានឹងសេចក្តីសម្រេចខាងក្រោមបានក្នុងរយៈពេល 15 ថ្ងៃគិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេច៖

- **សេចក្តីសម្រេចអំពីសវនាការវិន័យ**
  - សេចក្តីសម្រេចធ្វើឡើងដោយអនុលោមតាមសវនាការវិន័យ (សូមមើលផ្នែកវិន័យសិស្ស)
  - បើសិស្សបានទទួលការផ្ទេរទៅសាលាផ្សេង ឬកិច្ចការអប់រំជំនួសសម្រាប់យុវជនដែលរំខាន (AEDY) កិច្ចការនេះនៅតែមានសុពលភាពក្នុងអំឡុងពេលប្តឹងតវ៉ា។
- **ការដាក់សិស្សឲ្យរៀនបណ្តោះអាសន្នដើម្បីសុវត្ថិភាព**
  - សេចក្តីសម្រេចបានធ្វើឡើងដោយអនុលោមតាមការដាក់សិស្សឲ្យរៀនបណ្តោះអាសន្ន AEDY (សូមមើលផ្នែកវិន័យសិស្ស)
  - កិច្ចការបណ្តោះអាសន្ននៅតែមានសុពលភាពក្នុងអំឡុងពេលប្តឹងតវ៉ា។
- **ការកំណត់បញ្ហាគ្មានផ្ទះសម្បែង**
  - សេចក្តីសម្រេចត្រូវបានធ្វើឡើងដោយអនុលោមតាមសិទ្ធិទទួលបានក្រោមចំណងជើង X ផ្នែក C នៃច្បាប់ McKinney-Vento ស្តីពីជំនួយជនគ្មានផ្ទះសម្បែង
  - សិស្សដែលចូលរួមក្នុងដំណើរការដោះស្រាយវិវាទ McKinney-Vento មានសិទ្ធិចុះឈ្មោះចូលរៀនភ្លាមៗនៅក្នុងសាលាតាមជម្រើសដោយរង់ចាំការដោះស្រាយវិវាទ។
  - ប្រសិនបើមិនមានដំណោះស្រាយនៅកម្រិតមណ្ឌលសិក្សាធិការទេ វិវាទនេះនឹងផ្ទេរទៅកម្រិតថ្នាក់រដ្ឋសម្រាប់ការដោះស្រាយចុងក្រោយដែលសម្របសម្រួលដោយអ្នកសម្របសម្រួលថ្នាក់រដ្ឋនៃក្រសួងអប់រំរដ្ឋ Pennsylvania (PDE)។
- **លិខិតមិនឱ្យចូលសាលារៀន**
  - សេចក្តីសម្រេចបានធ្វើឡើងដោយមិនរាប់បញ្ចូលមាតាបិតា/អាណាព្យាបាលពីអគារសិក្សា (សម្រាប់ពេលវេលាជាក់លាក់) ដោយសារតែអាកប្បកិរិយាដែលបំពានលើក្រមសីលធម៌។
  - លិខិតមិនឱ្យចូលសាលារៀននៅតែមានសុពលភាពក្នុងអំឡុងពេលពិនិត្យបណ្តឹងតវ៉ា។

- **លទ្ធផលរកឃើញការប្រមាថ/ការបៀតបៀន**
    - សេចក្តីសម្រេចធ្វើឡើងលើលទ្ធផលរកឃើញនៃការស៊ើបអង្កេតលើការចោទប្រកាន់អំពីការប្រមាថ ការបៀតបៀន និង/ឬការរើសអើង។
    - សេចក្តីសម្រេចដែលបានធ្វើឡើងទាក់ទងនឹងបណ្តឹងផ្លូវការពីបទបៀតបៀនក្រោមចំណងជើង IX រួមទាំងការច្រានចោលពាក្យបណ្តឹងផ្លូវការក្រោមចំណងជើង IX និងការកំណត់សម្រាប់ពាក្យបណ្តឹងផ្លូវការក្រោមចំណងជើង IX។
- **ការជ្រើសរើសសាលា**
    - សេចក្តីសម្រេចដែលបានធ្វើឡើងដោយយោងទៅតាមសិទ្ធិជ្រើសរើសសាលារៀនអាចដាក់ពាក្យបណ្តឹងតវ៉ាជារៀងរាល់ឆ្នាំបានក្នុងអំឡុងពេលដាក់បណ្តឹងតវ៉ាអំពីការជ្រើសរើសសាលារៀន។ ព័ត៌មានស្តីពីដំណើរការបណ្តឹងតវ៉ាអំពីការជ្រើសរើសសាលានឹងផ្តល់ជូនក្នុងអំឡុងពេលដំណើរការពាក្យសុំជ្រើសរើសសាលារៀននៅលើគេហទំព័រ ការិយាល័យចុះឈ្មោះសិស្ស និងការដាក់សិស្សឲ្យរៀន ។ ព័ត៌មានស្តីពីដំណើរការបណ្តឹងតវ៉ាអំពីការជ្រើសរើសសាលានឹងផ្តល់ជូនក្នុងអំឡុងពេលដំណើរការពាក្យសុំជ្រើសរើសសាលារៀននៅលើគេហទំព័រ ការិយាល័យចុះឈ្មោះសិស្ស និងការដាក់សិស្សឲ្យរៀន។

ព័ត៌មានបន្ថែមអំពីដំណើរការបណ្តឹងតវ៉ា រួមទាំងទម្រង់បែបបទបណ្តឹងតវ៉ា អាចរកបាននៅលើគេហទំព័រ ការិយាល័យសិទ្ធិ និង ទំនួលខុសត្រូវរបស់សិស្ស។ មាតាបិតា/អាណាព្យាបាលអាចផ្ញើអ៊ីមែលទៅ appealsoffice@philasd.org ឬទាក់ទងតាមលេខ 215-400-4830 ដើម្បីសួរសំណួរ និង/ឬដើម្បីស្នើសុំទម្រង់បែបបទពាក្យបណ្តឹងតវ៉ា។ អ៊ីមែលទាំងអស់នឹងត្រូវបានឆ្លើយតបក្នុងរយៈពេល 24 ម៉ោង។

# ជំនួយគាំទ្រសិស្ស និងអាណាព្យាបាល

បន្ថែមពីលើសិទ្ធិ និងកិច្ចការពាររបស់សិស្ស និងមាតាបិតា/អាណាព្យាបាលមានធនធាន និងការិយាល័យបន្ថែម ដើម្បីគាំទ្រសុខុមាលភាព និងទទួលបានការអប់រំ។

### ការចូលរួមរបស់គ្រួសារ និងសហគមន៍

ការិយាល័យទាក់ទងនឹងការចូលរួមរបស់គ្រួសារ និងសហគមន៍ (FACE) ផ្តល់ជូននូវកម្មវិធី និងសេវាកម្មជាច្រើន ដើម្បីគាំទ្រដល់ការចូលរួមដ៏មានអត្ថន័យរបស់គ្រួសារទូទាំងមណ្ឌលសិក្សាធិការ និងភាគីពាក់ព័ន្ធសហគមន៍ជាមួយមណ្ឌលសិក្សាធិការ។ ការគាំទ្រទាំងនេះរួមមាន៖

- **អ្នកទំនាក់ទំនងការចូលរួមរបស់គ្រួសារ៖** សាលានីមួយៗមានអ្នកទំនាក់ទំនងការចូលរួមរបស់គ្រួសារដែលបានចាត់តាំង ដើម្បីផ្តល់ឱ្យសាលានូវយុទ្ធសាស្ត្រទំនាក់ទំនងគ្រួសារដែលជាការអនុវត្តដ៏ល្អបំផុត។ អ្នកទំនាក់ទំនងធ្វើការដោយផ្ទាល់ជាមួយក្រុមគ្រួសារ ដើម្បីជួយស្វែងយល់ពីមណ្ឌលសិក្សាធិការ ដោះស្រាយក្តីកង្វល់ និងផ្តល់ឱកាសសិក្សាអំពីតួនាទីជាមាតាបិតា និងធនធានសហគមន៍តាមរយៈសិក្ខាសាលាកម្រិតសាលា។ ដើម្បីទាក់ទងអ្នកទំនាក់ទំនងរបស់សាលាអ្នក ឬទាក់ទងបុគ្គលិកសាលាដែលអាចជួយដោះស្រាយតម្រូវការជាក់លាក់របស់អ្នកបាន សូមចូលទៅកាន់ GET គេហទំព័រទទួលជំនួយ។
- **សិក្ខាសាលាសម្រាប់គ្រួសារ៖** មណ្ឌលសិក្សាធិការផ្តល់សិក្ខាសាលាដោយឥតគិតថ្លៃសម្រាប់គ្រួសារ និងសមាជិកដទៃទៀតនៃសហគមន៍មណ្ឌលសិក្សាធិការ។
- **ការគាំទ្រពីអ្នកស្ម័គ្រចិត្ត៖** ស្វែងយល់បន្ថែមអំពីរបៀបដែលការិយាល័យចូលរួមរបស់គ្រួសារ និងសហគមន៍ (FACE) របស់មណ្ឌលសិក្សាធិការជួយគាំទ្របុគ្គលិកស្ម័គ្រចិត្តតាមគេហទំព័រ philasd.org/face/volunteer។
- **ការដោះស្រាយសំណួរ ឬកង្វល់៖** ការិយាល័យ FACE គ្រប់គ្រងដំណើរការដោះស្រាយកង្វល់នៃមណ្ឌលសិក្សាធិការ។ យើងណែនាំឱ្យមាតាបិតា និងក្រុមគ្រួសារទាក់ទងទៅគ្រូរបស់សិស្ស និងថ្នាក់ដឹកនាំសាលាជាមុនសិន ដើម្បីព្យាយាម និងធ្វើការជាមួយគ្នាដើម្បីដោះស្រាយសំណួរ ឬកង្វល់ណាមួយអំពីសិស្ស ឬសាលារបស់ពួកគេ។ ប្រសិនបើសំណួរ ឬក្តីកង្វល់នៅតែមិនអាចដោះស្រាយបាន បុគ្គលិក FACE អាចជួយដំណើរការដោះស្រាយ កង្វល់ណាមួយ ដើម្បីជួយស្វែងរកដំណោះស្រាយជាឧត្តមប្រយោជន៍របស់សិស្ស។
- **ទាក់ទងមណ្ឌលសិក្សាធិការ៖** បុគ្គលិកការិយាល័យ FACE ឆ្លើយការហៅទូរសព្ទ ឆ្លើយតបអ៊ីមែល និងផ្តល់សេវាកម្មដោយផ្ទាល់ដល់បុគ្គលដែលត្រូវការជំនួយដោយផ្ទាល់ពីមណ្ឌលសិក្សាធិការ។ មើលព័ត៌មានទំនាក់ទំនងនៅក្នុងសៀវភៅអាសយដ្ឋានការិយាល័យ។

### ការការពារ និងអន្តរាគមន៍

ការិយាល័យបង្ការ និងអន្តរាគមន៍ ផ្តល់ការគាំទ្រផ្សេងៗដល់សិស្ស ដើម្បីដោះស្រាយឧបសគ្គចំពោះការអប់រំរបស់ពួកគេ។ ការគាំទ្រទាំងនេះរួមមាន៖

- **ការប្រឹក្សាទាក់ទងនឹងសាលា៖** អ្នកប្រឹក្សាសាលាធ្វើការជាមួយអ្នកថែទាំ បុគ្គលិកសាលា និងដៃគូសហគមន៍ ដើម្បីធានាថាតម្រូវការរបស់សិស្សនឹងត្រូវបានបំពេញ។ ទីប្រឹក្សាតស៊ូមតិដើម្បីសុខុមាលភាពរបស់សិស្ស និងផ្តល់ធនធានដ៏មានតម្លៃសម្រាប់ការរីកចម្រើននៃការសិក្សាអប់រំ និងរីកចម្រើនផ្ទាល់ខ្លួនរបស់ពួកគេដោយជួយលុបបំបាត់ឧបសគ្គទាំងឡាយដែលសិស្សអាចជួបប្រទះ។ ទីប្រឹក្សាផ្តល់សេវានៅក្រោមបី (3) វិស័យ៖ ការសិក្សា ផ្នែកសង្គមនិងអារម្មណ៍ និងការត្រៀមចូលមហាវិទ្យាល័យ/ចាប់អាជីព។
- **សេវាកម្មសុខភាពអាកប្បកិរិយាដែលខ្លាំងជាងនេះ (IBHS)៖** សាលារៀននីមួយៗមានអ្នកផ្តល់សេវា IBHS ដើម្បីដោះស្រាយតម្រូវការរបស់យុវជនដែលផ្តល់កិច្ចអន្តរាគមន៍សមស្របតាមវ័យ ដោយមានការជូនដំណឹងអំពីការបាក់ស្បាតនិងការព្យាបាល ដើម្បីដោះស្រាយតម្រូវការសុខភាពអាកប្បកិរិយាដោយផ្តល់ការគាំទ្រសុខភាពអាកប្បកិរិយានៅក្នុងសាលារៀន ផ្ទះ និងសហគមន៍។
- **កម្មវិធី STEP រួមមានក្រុមសុខភាពផ្លូវចិត្តដែលគាំទ្រសាលារៀនតាមរយៈ** ការដោះស្រាយបញ្ហាសុខភាពផ្លូវចិត្ត និងតម្រូវការស្មុគស្មាញសម្រាប់សិស្ស និងគ្រួសារនៅក្នុងសាលា។
- **ផ្នែកទំនាក់ទំនងបង្ការ និងអន្តរាគមន៍ (P&I)៖** ផ្នែកទំនាក់ទំនង P&I គឺជាក្រុមគ្រូពេទ្យគ្លីនិកដែលគាំទ្រអ្នកប្រឹក្សាសាលា និងថ្នាក់ដឹកនាំសាលាជាមួយនឹងការដោះស្រាយតម្រូវការសុខភាពអាកប្បកិរិយារបស់សិស្ស។ ពួកគេផ្តល់ការពិគ្រោះយោបល់ផ្នែកគ្លីនិកសម្រាប់បញ្ហាអាសន្នសុខភាពអាកប្បកិរិយា និងសម្របសម្រួលការឆ្លើយតបនឹងឧប្បត្តិហេតុសំខាន់ៗនៅសាលារៀន។

### សេវាជនរងគ្រោះ
ប្រសិនបើសិស្សម្នាក់ជាជនរងគ្រោះនៃឧប្បត្តិហេតុទាក់ទងនឹងសាលារៀន សាលាគួរបង្កើត និងរៀបចំផែនការសុវត្ថិភាពសម្រាប់សិស្សនោះ ប្រសិនបើសមស្រប។ មាតាបិតា/អាណាព្យាបាលគួរតែចូលរួមក្នុងដំណើរការរៀបចំផែនការ និងរួមចំណែកដល់កំណែចុងក្រោយនៃផែនការនេះ។ មាតាបិតា/អាណាព្យាបាលត្រូវតែចុះហត្ថលេខា និងទទួលច្បាប់ចម្លងនៃផែនការនេះនៅពេលបានបញ្ចប់រួចរាល់។

សេវាជនរងគ្រោះបន្ថែមអាចត្រូវបានស្វែងរកតាមរយៈការិយាល័យ Safe Schools Advocate រដ្ឋ Pennsylvania។ អាចទាក់ទងមេធាវី Safe Schools Advocate ដោយផ្ទាល់នៅអាសយដ្ឋាន៖ 440 N. Broad Street (Suite 1198) តាមទូរសព្ទ៖ 1-877-730-6315 និង 215-656-5381 ឬតាមអ៊ីមែល៖ RA-OSSAPhiladelphia@pa.gov។ គ្រួសារក៏អាចទាក់ទងការិយាល័យអ្នកឯកទេសខាងជំនួយជនរងគ្រោះនៃសុវត្ថិភាពសាលានៃមណ្ឌលសិក្សាធិការតាមទូរសព្ទ៖ 215-400-6758.

### មជ្ឈមណ្ឌលអន្តរកាលសិស្ស
មជ្ឈមណ្ឌលអន្តរកាលសិស្ស (STC) បម្រើជាមជ្ឈមណ្ឌលស្វាគមន៍កណ្ដាលដែលមានទីតាំងនៅ 440 N. Broad Street សម្រាប់សិស្សដែលផ្លាស់ប្ដូរទៅមណ្ឌលសិក្សាធិការវិញពីផ្លូវមួយក្នុងចំណោមផ្លូវទាំងប្រាំ (5) ហើយត្រូវការកិច្ចការសាលាបន្ទាប់ពីចាប់ពី (សាមសិប) 30 ថ្ងៃឡើង។ សិស្សនឹងទទួលបានការប្រជុំអន្តរកាល និងសេវាកម្មគ្រប់គ្រងករណី។

ផ្លូវទៅកាន់ STC រួមមាន៖
- **មណ្ឌលព្យាបាលតាមលំនៅឋាន (RTF)៖** សិស្សដែលទទួលបានដីកាបង្គាប់របស់តុលាការ ឬបញ្ជូនដោយក្រសួងសេវាមនុស្ស ការព្យួរទោសអនីតិជនក្រុង Philadelphia ឬសុខភាពអាកប្បកិរិយាសហគមន៍ (CBH)។
- **ការថែទាំរួម៖** សិស្សជាកូនក្នុងបន្ទុក ឬជាអនីតិជនប្រព្រឹត្តល្មើសកំពុងផ្លាស់ប្ដូរពីមណ្ឌលថែទាំរួម ឬមណ្ឌលឃុំឃាំងដែលចេញដីកាបង្គាប់ដោយតុលាការ។
- **ការដេកពេទ្យរយៈពេលវែង៖** សិស្សត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ និងទៅព្យាបាលជំងឺផ្លូវចិត្ត/ជំងឺអាកប្បកិរិយា និង/ឬសម្រាកព្យាបាលមួយផ្នែកនៅមន្ទីរពេទ្យ
- **ផ្ទះ ឬទីជម្រកធនធាន៖** សិស្សត្រលប់មកពីកន្លែងក្រៅពីមណ្ឌលសិក្សាធិការ ហើយដាក់នៅក្នុងមណ្ឌលចិញ្ចឹមថែទាំ ឬជម្រក។
- **ការបញ្ជូនបន្ត AEDY៖** សិស្សដែលត្រលប់ទៅសាលា SDP បន្ទាប់ពីបានបញ្ចប់កម្មវិធីអប់រំជំនួសសម្រាប់យុវជនដែលរំខាន (AEDY)។

### មជ្ឈមណ្ឌលភ្ជាប់ទំនាក់ទំនងឡើងវិញ
មជ្ឈមណ្ឌលភ្ជាប់ទំនាក់ទំនងឡើងវិញ (REC) គឺជាហាង "ច្រកចេញចូលតែមួយ" ដែលផ្ដល់ការប្រឹក្សា សេវាកម្មបញ្ជូនបន្តរបស់សាលារៀន និងព័ត៌មាន ដែលនាំទៅដល់ការចុះឈ្មោះចូលរៀនឡើងវិញក្នុងកម្មវិធីឌីប្លូមនៅមធ្យមសិក្សា ឬកម្មវិធី GED។ REC ភ្ជាប់ទំនាក់ទំនងជាមួយសិស្សដែលបោះបង់ការសិក្សា និងអ្នកដែលកំពុងប្រឈមនឹងគ្រោះថ្នាក់នៃការបោះបង់ការសិក្សា ជាមួយនឹងកម្មវិធីជាច្រើនប្រភេទ ដែលផ្ដល់ឱ្យសិស្សនូវជម្រើសជាច្រើនក្នុងការបំពេញលក្ខខណ្ឌតម្រូវនៃការបញ្ចប់ការសិក្សារបស់ពួកគេ។ ដើម្បីទាក់ទង REC សូមចូលទៅកាន់ គេហទំព័រ REC ហើយចុច “ចាប់ផ្ដើម” ដើម្បីបំពេញទម្រង់បែបបទចុះឈ្មោះ។

## ការប្រមាថ ការបៀតបៀន ការរើសអើង និងចំណងជើង IX

មណ្ឌលសិក្សាធិការទទួលស្គាល់ថាមានផលប៉ះពាល់អវិជ្ជមានពីការប្រមាថ ការបៀតបៀន និង/ឬការរើសអើងទៅលើសុខភាព សុខុមាលភាព និងសុវត្ថិភាពរបស់សិស្ស និងទៅលើបរិយាកាសសិក្សា។ រាល់ទង្វើបែបនេះត្រូវបានហាមឃាត់ដោយច្បាប់ និង គោលនយោបាយក្រុមប្រឹក្សាភិបាលឧទាហរណ៍ គោលនយោបាយលេខ 248 គោលនយោបាយលេខ 249 និងគោលនយោបាយលេខ 252 ។

### ចំណងជើង IX
ចំណងជើង IX គឺជាច្បាប់សហព័ន្ធដែលហាមឃាត់ការរើសអើងដោយផ្អែកលើភេទ ដែលរួមបញ្ចូល ការរំលោភផ្លូវភេទ និងរូបភាពផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទ ការប្រព្រឹត្តចំពោះសិស្សដែលមានផ្ទៃពោះ និងធ្វើជាមាតាបិតា និងការប្រព្រឹត្តចំពោះសិស្ស LGBTQI+។

ប្រសិនបើមានកង្វល់ ឬសំណួរទាក់ទងនឹងចំណងជើង IX សូមទាក់ទង៖

**ការសាកសួរទាក់ទងនឹងសិស្ស៖**
Andrea Prince, មន្ត្រីអនុលោមភាព/អ្នកសម្របសម្រួលចំណងជើង IX
antiharassment@philasd.org
440 N. Broad Street, Phila, PA 19130

**ការសាកសួរទាក់ទងនឹងនិយោជិត៖**
Michelle Chapman, សហអ្នកសម្របសម្រួលចំណងជើង IX
*employeerelations@philasd.org*
*400 N. Broad Street, Phila, PA 19130*

### ការរាយការណ៍
សមាជិកសហគមន៍សាលាណាមួយអាចរាយការណ៍ពីការប្រមាថ ការបៀតបៀន និង/ឬ ការរើសអើង ហើយរបាយការណ៍ទាំងអស់នឹងត្រូវបាន ស៊ើបអង្កេតដោយមិនគិតថាតើទទួលបានពាក្យបណ្តឹងដោយរបៀបណានោះទេ។

មានវិធីជាច្រើនដើម្បីធ្វើសេចក្តីរាយការណ៍៖
- ការបំពេញ ទម្រង់បែបបទរបាយការណ៍តាមអនឡាញអំពីការប្រមាថ ការបៀតបៀន និងការរើសអើង
- ការហៅទូរសព្ទទៅខ្សែទូរសព្ទទាន់ហេតុការណ៍អំពីការប្រមាថ ការបៀតបៀន និងការរើសអើង តាមរយៈលេខ 215-400-SAFE។
- ការដាក់ពាក្យបណ្តឹងតាមរយៈ Safe2Say ឬតាមទូរសព្ទលេខ 1-844-SAF2SAY (723-2729)
- ការផ្ញើអ៊ីមែលទៅមន្ត្រីអនុលោមភាព/អ្នកសម្របសម្រួលចំណងជើង IX ដោយផ្ទាល់តាម antiharassment@philasd.org
- ការរាយការណ៍ពីឧប្បត្តិហេតុនេះទៅកាន់នាយកសាលា ឬអ្នកតំណាង ឬទៅសមាជិកផ្សេងទៀតនៃបុគ្គលិកសាលា រួមទាំងគ្រូបង្រៀន អ្នកប្រឹក្សាណែនាំ ជំនួយការប្រឹក្សាពីរភាសា (BCAs) គ្រូបង្វឹក និងក្រុមថ្នាក់ដឹកនាំសាលា។

*ប្រសិនបើមាតាបិតា/អាណាព្យាបាល ឬសិស្សបានដាក់ពាក្យបណ្តឹងហើយមិនបានទទួលសេចក្តីសម្រេចបន្ទាប់ពី 7 ថ្ងៃសិក្សា សូមផ្ញើអ៊ីមែលទៅ antiharassment@philasd.org.

## ការស៊ើបអង្កេត

មណ្ឌលសិក្សាធិការយកចិត្តទុកដាក់ខ្ពស់លើបទល្មើសទាំងអស់នៃក្រមសីលធម៌។ នាយកសាលា ឬអ្នកតំណាងត្រូវតែធ្វើការស៊ើបអង្កេតលើការរំលោភបំពានលើក្រមសីលធម៌ដែលត្រូវបានចោទប្រកាន់ណាមួយ។ នេះរាប់បញ្ចូលទាំងទង្វើដែលកើតឡើងនៅក្រៅសាលារៀន តាមអនឡាញ និង/ឬក្រោយម៉ោងសិក្សា (រួមទាំងថ្ងៃចុងសប្តាហ៍) ប្រសិនបើការប្រព្រឹត្តប៉ះពាល់ខ្លាំងដល់សហគមន៍សាលារៀន (មានន័យថាការប្រព្រឹត្តមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ ឬច្រើនគួរសម)។

គោលការណ៍ណែនាំខាងក្រោមអនុវត្តចំពោះការស៊ើបអង្កេត៖
- មាតាបិតា/អាណាព្យាបាលត្រូវតែទទួលបានការជូនដំណឹងអំពីឧប្បត្តិហេតុធ្ងន់ធ្ងរទាំងអស់ដែលពាក់ព័ន្ធនឹងសិស្សរបស់ពួកគេ ទោះជាយ៉ាងណាក៏ដោយសាលាមិនត្រូវការការអនុញ្ញាតពីមាតាបិតា/អាណាព្យាបាល ដើម្បីធ្វើការស៊ើបអង្កេត ឬទទួលបានចម្លើយដែលទាក់ទងនឹងទង្វើដែលត្រូវបានចោទប្រកាន់នោះទេ។
- អនុលោមតាម គោលនយោបាយគណៈកម្មការលេខ 226 រដ្ឋបាលសាលាអាច "ឆែក" សិស្ស និង/ឬរបស់របររបស់ពួកគេ ប្រសិនបើមានការសង្ស័យសមហេតុផលថា សិស្សមានរបស់ដែលហាមឃាត់។
- ប្រសិនបើទង្វើនេះរួមមានការគំរាមកំហែងប្រើប្រាស់អាវុធ សម្លាប់ ឬធ្វើឱ្យរបួសរាងកាយធ្ងន់ធ្ងរដោយចេតនា/ផែនការ សាលារៀនត្រូវតែអនុវត្តតាមដំណើរការវាយតម្លៃការគំរាមកំហែងរបស់មណ្ឌលសិក្សាធិការ ដោយទាក់ទងទៅការិយាល័យសុវត្ថិភាពសាលារៀន។
- ប្រសិនបើពាក្យបណ្តឹងរួមបញ្ចូលការចោទប្រកាន់អំពីការបៀតបៀនផ្លូវភេទ អំពើហិង្សាផ្លូវភេទ ឬការបៀតបៀនដោយផ្អែកលើទំនោរផ្លូវភេទ សូមជូនដំណឹងដល់អ្នកសម្របសម្រួលចំណងជើង IX មុនពេលបន្តស៊ើបអង្កេត ឬដាក់វិន័យ។
- ទង្វើដែលបានចោទប្រកាន់មួយចំនួនអាចទាមទារការជូនដំណឹងទៅនាយដ្ឋានប៉ូលិសក្រុង Philadelphia សាលារៀនត្រូវប្រឹក្សាជាមួយមន្ត្រីសុវត្ថិភាពសាលារៀន និង/ឬអ្នកគ្រប់គ្រងតំបន់ដើម្បីណែនាំ។
- ទង្វើដែលបានចោទប្រកាន់មួយចំនួនអាចទាមទារការជូនដំណឹងទៅកាន់ Childline ខណៈដែលបុគ្គលិកមណ្ឌលសិក្សាធិការគឺជាអ្នករាយការណ៍ដែលបានតម្រូវ។
- ពេលខ្លះ វាអាចចាំបាច់ក្នុងការចែករំលែកព័ត៌មានមួយចំនួនអំពីឧប្បត្តិហេតុធ្ងន់ធ្ងរជាមួយសហគមន៍សាលា (មាតាបិតា/អាណាព្យាបាល និងសិស្ស)។ សាលារៀនគួរតែធ្វើកិច្ចប្រជុំជាមួយជំនួយការប្រធាននាយកដែលនឹងទាក់ទងទៅការិយាល័យទំនាក់ទំនង នៅពេលពិចារណាថាតើលិខិត/សារទំនាក់ទំនងនឹងផ្ញើចេញឬអត់។
- ក្នុងករណីខ្លះ អ្នកស៊ើបអង្កេតមកពីការិយាល័យកណ្តាលនឹងដឹកនាំ ឬចូលរួមក្នុងការស៊ើបអង្កេត។
- សាលារៀនគួរតែបញ្ជូនទៅអ្នកស៊ើបអង្កេតនៃ ការិយាល័យសិទ្ធិ និងទំនួលខុសត្រូវរបស់សិស្ស សម្រាប់ការណែនាំពេញលេញស្តីពីការស៊ើបអង្កេត។

## អាកប្បកិរិយា និងវិន័យរបស់សិស្ស

បរិយាកាសសាលាដែលមានលក្ខណៈវិជ្ជមាន សមធម៌ និងដែលគាំទ្រសិស្សក្នុងការកសាងជំនាញសង្គម-អារម្មណ៍ និងទំនាក់ទំនងរឹងមាំអាចបណ្តាលឱ្យមាន៖ ការថយចុះអាកប្បកិរិយារំខាន បង្កើនការចូលរួមរបស់សិស្ស ធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សា និងអន្តរកម្មវិជ្ជមានបន្ថែមទៀតរវាង និងក្នុងចំណោមបុគ្គលិក និងសិស្ស។
នៅក្នុងមណ្ឌលសិក្សាធិការ សាលាទាំងអស់អនុវត្ត វិធីសាស្ត្របរិយាកាសទូទាំងសាលា ផ្អែកលើភស្តុតាង៖ ទំនាក់ទំនងដំបូង (RF) អន្តរកម្មនិងការគាំទ្រអាកប្បកិរិយាវិជ្ជមានដែលឆ្លើយតបទៅនឹងវប្បធម៌ (CR-PBIS) និងការសិក្សាអំពីសង្គមអារម្មណ៍ទូទាំងសាលា (SEL)។

នៅពេលដែលអាកប្បកិរិយារំខានកើតឡើង សាលាត្រូវតែឆ្លើយតបដោយមើល **ម៉ាទ្រីសអាកប្បកិរិយា** (សូមមើលឧបសម្ព័ន្ធ) ហើយធ្វើការសម្រេចចិត្តដោយអនុលោមតាមវិធីសាស្រ្តដាក់វិន័យរបស់មណ្ឌលសិក្សាធិការ៖

- ឧបទ្ទវហេតុទាក់ទងនឹងអាកប្បកិរិយាគួរតែចាត់ទុកជាឱកាសសម្រាប់ការរៀនសូត្រ និងរីកចម្រើន។
- លើកលែងតែករណីល្មើសធ្ងន់ធ្ងរបំផុត រាល់ឧប្បត្តិហេតុទាំងអស់គួរតែដោះស្រាយតាមរយៈវិធីសាស្រ្តស្តារនីតិសម្បទា។
- វិធីសាស្រ្តស្តារនីតិសម្បទាគឺផ្តោតលើការបង្រៀន និងការព្យាបាល ជាជាងការដាក់ទណ្ឌកម្ម។
- សាលាគួរតែប្រើប្រាស់វិធីសាស្រ្តផ្អែកលើសាលាមុននឹងងាកទៅរកវិធីដកសិស្ស។ ក្នុងករណីដែលការមិនឲ្យចូលសាលារៀនគឺសមស្រប អន្តរាគមន៍បន្ថែមក៏ត្រូវតែអនុវត្តនៅនឹងកន្លែងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីវិធីសាស្រ្តដាក់វិន័យសិស្សរបស់មណ្ឌលសិក្សាធិការ សូមចូលទៅកាន់គេហទំព័រ ការិយាល័យសិទ្ធិ និង ទំនួលខុសត្រូវរបស់សិស្ស។

សម្រាប់ព័ត៌មានបន្ថែមអំពីការគាំទ្រ និងអន្តរាគមន៍សុខភាពអាកប្បកិរិយា សូមចូលទៅកាន់គេហទំព័រ ការិយាល័យបង្ការ និងអន្តរាគមន៍។

<table>
<tr><th colspan="2">ការឆ្លើយតបនឹងអាកប្បកិរិយាផ្អែកតាមសាលា</th></tr>
<tr><th colspan="2">កម្រិតទី 1 - ការឆ្លើយតបរបស់គ្រូបន្ទុកថ្នាក់</th></tr>
<tr><td>• ការធ្វើគំរូ<br>• ការបញ្ជូនបន្ត<br>• បង្រៀន និងបង្រៀនឡើងវិញពីការរំពឹងទុក<br>• ការសរសើរចំៗ<br>• រង្វាន់/ការលើកទឹកចិត្ត<br>• ថ្នាក់រៀន "ការងារ"<br>• យុទ្ធសាស្រ្តនៃការតាំងសមាធិ<br>• ការបង្រៀនច្បាស់លាស់អំពី SEL</td><td>• យុទ្ធសាស្រ្តកាត់បន្ថយការតានតឹងចិត្ត<br>• ការសន្ទនាស្តារនីតិសម្បទា<br>• ការហៅទូរសព្ទទៅផ្ទះ<br>• ការផ្លាស់ប្តូរកន្លែងអង្គុយ<br>• ការបាត់បង់ឯកសិទ្ធិក្នុងថ្នាក់រៀន<br>• សេវាកម្ម/គម្រោងសហគមន៍<br>• ប្រព័ន្ធ "គ្រូជាមិត្ត"</td></tr>
<tr><th colspan="2">កម្រិតទី 2 - ការឆ្លើយតបរបស់គ្រូបន្ទុកថ្នាក់ និង/ឬរដ្ឋបាល</th></tr>
<tr><td>• កិច្ចប្រជុំជាមួយមាតាបិតា<br>• ការឃុំឃាំង និងការឆ្លុះបញ្ចាំង<br>• បន្ទប់ឆ្លុះបញ្ចាំង<br>• វដ្តនៃភាពអន្តរាយ និងការព្យាបាល<br>• ការសម្រុះសម្រួល/ការសម្រុះសម្រួលជាមួយមិត្ត<br>• ការណែនាំ<br>• តុលាការយុវជន<br>• គម្រោងស្តារនីតិសម្បទា</td><td>• កិច្ចសន្យាអាកប្បកិរិយា<br>• ចុះវត្តមានចូល/ចុះវត្តមានចេញ<br>• របាយការណ៍ប្រចាំថ្ងៃ<br>• ការបញ្ជូនទៅកាន់អ្នកប្រឹក្សា<br>    ◦ អន្តរាគមន៍ក្រុមតូច<br>• ការបញ្ជូនទៅកាន់អ្នកប្រឹក្សា៖ កម្មវិធីជំនួយសិស្ស<br>• សេវាបង្ការដែលខ្លាំងជាងនេះផ្អែកតាមសហគមន៍ (IPS)</td></tr>
<tr><th colspan="2">កម្រិតទី 3- ការឆ្លើយតបរបស់រដ្ឋបាល</th></tr>
<tr><td>• វដ្តនៃការគាំទ្រ និងគណនេយ្យភាព (COSA)<br>• ការព្យួរការសិក្សាក្នុងសាលា<br>• ផែនការសុវត្ថិភាព ដែលអាចរួមបញ្ចូល៖<br>    ◦ ការបង្កើនការត្រួតពិនិត្យ<br>    ◦ ការតាមដាន<br>    ◦ ការផ្លាស់ប្តូរកាលវិភាគរៀន</td><td>• ការបញ្ជូនទៅកាន់អ្នកប្រឹក្សា៖<br>    ◦ សេវាសុខភាពអាកប្បកិរិយាដែលខ្លាំងជាងនេះ<br>    ◦ ផែនការ 504<br>    ◦ វិបត្តិ (ភាពអាសន្នសុខភាពអាកប្បកិរិយា)<br>• ការបញ្ជូនទៅទទួលការអប់រំពិសេស៖<br>    ◦ ការវាយតម្លៃគ្រប់ជ្រុងជ្រោយ ឬការវាយតម្លៃឡើងវិញ<br>    ◦ ការវាយតម្លៃអាកប្បកិរិយាមុខងារ (FBA) និងផែនការគាំទ្រ និងអាកប្បកិរិយាវិជ្ជមាន (PBSP)</td></tr>
</table>

បន្ថែមពីលើការឆ្លើយតបទៅនឹងអាកប្បកិរិយានៅសាលារៀន សាលារៀនអាចកំណត់ថា វិន័យមិនឲ្យចូលរៀនគឺសមស្របសម្រាប់ហេតុផលសុវត្ថិភាព។ ទាក់ទងទៅនឹងវិន័យមិនឲ្យចូលរៀន ការស្រាវជ្រាវបង្ហាញថា យុវជនស្បែកខ្មៅច្រើនតែទំនងជាត្រូវបានបណ្តេញចេញពីសាលាបី (3) ដងច្រើនជាងមិត្តស្បែកសរបស់ពួកគេ ហើយសិស្សដែលមានពិការភាពគឺច្រើនតែទំនងជាត្រូវបានព្យួរការសិក្សាក្រៅសាលាពីរ (2) ដងច្រើនមិត្តស្បែកសរបស់ពួកគេ។ មណ្ឌលសិក្សាធិការមិនគាំទ្រការប្រើប្រាស់គោលនយោបាយអត់ឱនដែលតម្រូវឱ្យបុគ្គលិកសាលាព្យួរការសិក្សា ឬបណ្តេញសិស្សចេញដោយសារអាកប្បកិរិយាមួយចំនួនលើកលែងតែតម្រូវដោយច្បាប់។ មណ្ឌលសិក្សាធិការប្តេជ្ញាធ្វើឱ្យប្រសើរឡើងនូវសមធម៌អប់រំ និងកាត់បន្ថយវិសមាមាត្រពូជសាសន៍ក្នុងការដាក់វិន័យទណ្ឌកម្ម និងមិនឲ្យចូលរៀន ដែលរួមមានការបណ្តេញសិស្សចេញពីសាលារបស់ពួកគេ។

## នីតិវិធីព្យួរការសិក្សា

យោងតាមច្បាប់រដ្ឋ Pennsylvania ការព្យួរការសិក្សាត្រូវបានកំណត់ថាជាការបដិសេធសិស្សនូវសិទ្ធិចូលរៀន និងចូលរួមក្នុងកម្មវិធីសាលាណាមួយសម្រាប់រយៈពេលរហូតដល់ដប់ (10) ថ្ងៃសិក្សាជាប់ៗគ្នា។ ការព្យួរការសិក្សាទាំងអស់ត្រូវតែធ្វើឡើងមុនដោយជូនដំណឹងដល់សិស្ស និងមាតាបិតា/អាណាព្យាបាលជាលាយលក្ខណ៍អក្សរស្របតាមច្បាប់រដ្ឋ។

<u>ការព្យួរការសិក្សាក្នុងសាលា</u>

ការព្យួរការសិក្សាក្នុងសាលា (ISS) គឺជាការបណ្តេញចេញពីថ្នាក់រៀន និងអនុញ្ញាតឱ្យសិស្សបន្តស្ថិតក្រោមការត្រួតពិនិត្យផ្ទាល់ពីបុគ្គលិកសាលា។ ការត្រួតពិនិត្យផ្ទាល់មានន័យថាបុគ្គលិកសាលាស្ថិតនៅក្នុងទីតាំងតែមួយជាមួយនឹងសិស្សដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ពួកគេ។ សិស្សដែលចូលរួមក្នុងការព្យួរការសិក្សាក្នុងសាលានឹងមានឱកាសបំពេញកិច្ចការ ក៏ដូចជាការឆ្លុះបញ្ចាំងដែលទាក់ទងនឹងអាកប្បកិរិយារបស់ពួកគេដែលបានជំរុញឲ្យព្យួរការសិក្សាក្នុងសាលា (ISS)។ សាលារៀនទាំងអស់ប្រហែលជាមិនមានបុគ្គលិកជួយសម្រួលដល់ការព្យួរការសិក្សាក្នុងសាលា (ISS) ទេ ដូច្នេះហើយ នេះប្រហែលជាមិនតែងតែជាជម្រើសដាក់វិន័យឡើយ។

<u>ការព្យួរការសិក្សាក្រៅសាលា</u>

ថ្នាក់មត្តេយ្យ ថ្នាក់ទីមួយ និងថ្នាក់ទីពីរមិនអាចត្រូវព្យួរការសិក្សាបានទេ លុះត្រាតែសកម្មភាពរបស់ពួកគេបណ្តាលឱ្យមានរបួសរាងកាយធ្ងន់ធ្ងរដោយចេតនា ដោយចងក្រងជាឯកសារ។ សាលារៀនត្រូវតែពិគ្រោះយោបល់ជាមួយការិយាល័យសិទ្ធិ និងទំនួលខុសត្រូវរបស់សិស្ស មុននឹងធ្វើការព្យួរការសិក្សារបស់សិស្សក្នុងថ្នាក់ទាំងនេះ។ លើសពីនេះ សិស្សត្រូវបញ្ជូនទៅកាន់អ្នកប្រឹក្សាសម្រាប់អន្តរាគមន៍ និងការគាំទ្រផ្នែកសុខភាពអាកប្បកិរិយាសមស្រប។ មាតាបិតា/អាណាព្យាបាលត្រូវបានស្នើសុំឱ្យសហការជាដៃគូជាមួយសាលាដើម្បីដោះស្រាយបញ្ហាអាកប្បកិរិយា។

សិស្សថ្នាក់ទីបី (3) ដល់ថ្នាក់ទីដប់ពីរ (12) អាចត្រូវបានព្យួរការសិក្សានៅពេលដែលពួកគេបានរំលោភលើក្រមសីលធម៌ ហើយការព្យួរការសិក្សាត្រូវបានចាត់ទុកថាសមរម្យសម្រាប់អាកប្បកិរិយានោះ។

- **ការព្យួរការសិក្សារយៈពេលខ្លី៖** ការបណ្តេញចេញពីសាលារៀន និង/ឬសកម្មភាព ឬកម្មវិធីរបស់សាលាសម្រាប់រយៈពេលពីមួយ (1) ទៅបី (3) ថ្ងៃសិក្សា។
- **ការព្យួរការសិក្សារយៈពេលវែង៖** ការបណ្តេញចេញពីសាលារៀន និង/ឬសកម្មភាព ឬកម្មវិធីរបស់សាលាសម្រាប់រយៈពេលពីបួន (4) ទៅដប់ (10) ថ្ងៃសិក្សា។ សាលារៀនត្រូវតែពិគ្រោះជាមួយជំនួយការប្រធាននាយក និងការិយាល័យសិទ្ធិ និងទំនួលខុសត្រូវរបស់សិស្សមុននឹងធ្វើការផ្អាកការសិក្សារយៈពេលវែង។

សិស្សម្នាក់មិនអាច ត្រូវបានបណ្តេញចេញ ពីសាលាបានទេ លុះត្រាតែមានរៀបចំឯកសារអំពីការផ្អាកការសិក្សា។ ការបណ្តេញចេញពីសាលារួមមាន៖ ការបញ្ជូនសិស្សទៅផ្ទះ ការមិនអនុញ្ញាតឱ្យសិស្សត្រលប់ទៅអគារសិក្សាវិញ (ក្នុងករណីដែលពួកគេចាកចេញពីអគារសិក្សាដោយគ្មានការអនុញ្ញាត) ការស្នើសុំឱ្យសិស្សស្នាក់នៅផ្ទះមិនមកសាលារៀនក្នុងរយៈពេលប៉ុន្មានថ្ងៃដោយមាន ឬគ្មានការបង្រៀនតាមអនឡាញ។

គោលការណ៍ណែនាំខាងក្រោមអនុវត្តចំពោះការព្យួរការសិក្សាក្រៅសាលា (OSS) ទាំងអស់៖
- សិស្សត្រូវតែជួបជាមួយនាយកសាលា ឬអ្នកតំណាងមុនការព្យួរការសិក្សានេះ លុះត្រាតែច្បាស់ថា សុខភាព និងសុវត្ថិភាពនៃសហគមន៍សាលាត្រូវបានប៉ះពាល់។
- នៅពេលដែលសិស្សម្នាក់ត្រូវបានបណ្តេញចេញពីសាលារៀនជាការឆ្លើយតបទៅនឹងអាកប្បកិរិយាមិនសមរម្យ ការបណ្តេញចេញនេះនឹងរាប់ជាថ្ងៃដំបូងនៃការព្យួរការសិក្សាក្រៅសាលា (OSS)។
- មាតាបិតា/អាណាព្យាបាលត្រូវតែទទួលបានការជូនដំណឹង ហើយលិខិតជូនដំណឹងអំពីការព្យួរការសិក្សាត្រូវតែចេញនៅពេលព្យួរការសិក្សា។
- កិច្ចការសាលាត្រូវតែផ្តល់ឲ្យសិស្សដោយបុរេសកម្ម ប្រសិនបើការព្យួរការសិក្សានេះនឹងលើសពីបួន (4) ថ្ងៃ ហើយកិច្ចការគួរតែបញ្ចប់ត្រឹមពេលចូលសាលាវិញ។
- ការព្យួរការសិក្សាគឺជាការអវត្តមានមានច្បាប់ ហើយមិនអាចកត់ត្រាថា "គ្មានច្បាប់" បានទេ។
- កិច្ចប្រជុំជាមួយមាតាបិតាសិស្សគួរតែកំណត់ពេលមុន ឬពេលសិស្សចូលសាលាវិញ។ ទោះជាយ៉ាងណាក៏ដោយ កិច្ចប្រជុំជាមួយមាតាបិតាសិស្សមិនអាចទាមទារជាលក្ខខណ្ឌនៃការចូលសាលាវិញទេ។ សិស្សត្រូវតែទទួលបានការអនុញ្ញាតឱ្យចូលសាលារៀនវិញនៅពេលបញ្ចប់ការព្យួរការសិក្សារបស់ពួកគេ។
- សិស្សដែលកំពុងជាប់ការព្យួរការសិក្សាក្រៅសាលាមិនត្រូវបានអនុញ្ញាតឱ្យចូលបរិវេណសាលា ចូលរួមក្នុងសកម្មភាពក្រៅកម្មវិធីសិក្សា ឬចូលរួមកម្មវិធីដែលសាលាឧបត្ថម្ភឡើយ។
- សិស្សអាចត្រូវបានចាត់ទុកថាល្មើសប្រសិនបើពួកគេចូលមកក្នុងបរិវេណសាលាខណៈពេលកំពុងជាប់ OSS។

## នីតិវិធីនៃកិច្ចប្រជុំជាមួយមាតាបិតា/អាណាព្យាបាលសិស្ស

សាលាត្រូវតែប្រកាន់ខ្ជាប់នូវនីតិវិធីដូចខាងក្រោមនៅពេលរៀបចំកិច្ចប្រជុំជាមួយមាតាបិតាសិស្ស ដើម្បីដោះស្រាយបញ្ហាអាកប្បកិរិយា៖

- សេចក្ដីជូនដំណឹងអំពីកិច្ចប្រជុំនេះត្រូវតែផ្ដល់ជូនមាតាបិតា/អាណាព្យាបាលជាលាយលក្ខណ៍អក្សរ ជាភាសាដែលគេចង់បាន ហើយផ្ញើតាមប្រៃសណីយ៍ អ៊ីមែល ឬតាមមធ្យោបាយសមស្របផ្សេងទៀត។
- មាតាបិតា/អាណាព្យាបាលត្រូវបានរំពឹងថានឹងចូលរួមកិច្ចប្រជុំទាំងអស់ដែលបានកំណត់ពេល ហើយថ្នាក់ដឹកនាំសាលាគួរតែព្យាយាមគ្រប់បែបយ៉ាងដើម្បីចូលរួមជាមួយអាណាព្យាបាលដើម្បីឱ្យពួកគេអាចចូលរួមដោយផ្ទាល់ ឬអនឡាញ តាមតម្រូវការ។
- ការបកប្រែផ្ទាល់មាត់នឹងត្រូវបានផ្ដល់ជូនប្រសិនបើមានការស្នើសុំ។
- គោលបំណងនៃកិច្ចប្រជុំនេះគួរតែពិភាក្សាអំពីបញ្ហាអាកប្បកិរិយា/ឧប្បត្តិហេតុ និងផ្ដល់សេវាគាំទ្រតាមតម្រូវការ។
- មាតាបិតា/អាណាព្យាបាលអាចស្នើសុំច្បាប់ចម្លងនៃកំណត់ត្រាសិស្ស និងភស្តុតាងណាមួយដែលទាក់ទងនឹងឧប្បត្តិហេតុនេះបាន។
  - សេចក្ដីថ្លែងការណ៍ត្រូវតែកែសម្រួលឡើងវិញមុនពេលអាចផ្ដល់ជូនមាតាបិតា/អាណាព្យាបាលបាន។
  - រូបថត និងការថតវីដេអូនៃឧប្បត្តិហេតុនេះអាចបង្ហាញបាន ប៉ុន្តែមិនអាចផ្ដល់ច្បាប់ចម្លងបានទេ។
- ថ្នាក់ដឹកនាំសាលានឹងជូនដំណឹងដល់មាតាបិតា/អាណាព្យាបាលអំពីចំណាត់ការវិន័យបន្ថែមណាមួយ និងផ្ដល់នូវទិដ្ឋភាពទូទៅអំពីសិទ្ធិទទួលបាននីតិវិធីត្រឹមត្រូវទាក់ទងនឹងចំណាត់ការវិន័យ។

## ដំណើរការសវនាការវិន័យ

សវនាការវិន័យអនុវត្តចំពោះសិស្សថ្នាក់ទីប្រាំមួយ (6) ដល់ទីដប់ពីរ (12) ប៉ុណ្ណោះ។ សិស្សថ្នាក់មត្តេយ្យដល់ថ្នាក់ទីប្រាំ (5) មិនអាចត្រូវបានបញ្ជូនទៅទទួលសវនាការវិន័យបានទេ ដូច្នេះហើយមិនអាចទទួលបានការផ្ទេរទៅក្រៅឬដោយដាក់វិន័យ នោះទេ។

សិស្សដែលកំពុងបង្ហាញលំនាំនៃអាកប្បកិរិយារំខាន និង/ឬបានប្រព្រឹត្តការរំលោភធ្ងន់ធ្ងរលើក្រមសីលធម៌អាចត្រូវបានបញ្ជូនទៅការិយាល័យសិទ្ធិ និងទំនួលខុសត្រូវរបស់សិស្សទទួលសវនាការវិន័យរបស់សិស្ស។ មុននឹងធ្វើការបញ្ជូន សាលាត្រូវតែបញ្ចប់ការត្រួតពិនិត្យការអនុវត្តអាកប្បកិរិយា (BPR) សម្រាប់សិស្សអប់រំចំណេះទូទៅ ដើម្បីកំណត់ថាតើសិស្សត្រូវបានគិតថាមានពិការភាពដែរឬទេ។ សិស្សមានសិទ្ធិត្រលប់ទៅសាលាវិញដោយរង់ចាំលទ្ធផលនៃសវនាការ លុះត្រាតែពួកគេត្រូវបានយល់ព្រមឲ្យដាក់ឲ្យចូលរៀនបណ្ដោះអាសន្នដើម្បីសុវត្ថិភាព និងទទួលបានលិខិតទាក់ទងនឹងកិច្ចការឬដែលដាក់ឱ្យចូលរៀន។

<u>ការដាក់ឲ្យចូលរៀនបណ្ដោះអាសន្នដើម្បីសុវត្ថិភាព</u>

- សាលាអាចស្នើសុំឲ្យដាក់ចូលរៀនបណ្ដោះអាសន្នដើម្បីសុវត្ថិភាព (ការផ្ទេរសាលាបណ្ដោះអាសន្ន) ទៅកាន់កម្មវិធីអន្តរកាលសម្រាប់ការអប់រំជំនួសសម្រាប់យុវជនដែលរំខាន (AEDY) សម្រាប់ស្ថានភាពដែលបានដាក់កំហិត ដែលសាលាបានរៀបចំឯកសារបញ្ជាក់ថា អាកប្បកិរិយារបស់សិស្សបង្កការគំរាមកំហែងជាបន្តបន្ទាប់ដល់សហគមន៍សាលា។
- ប្រសិនបើការដាក់ឱ្យចូលរៀនបណ្ដោះអាសន្នត្រូវបានផ្ដល់ដោយការិយាល័យសិទ្ធិ និងទំនួលទទួលខុសត្រូវរបស់សិស្ស សវនាការត្រូវតែកំណត់ពេលភ្លាមៗ។
- សិស្សដែលមានពិការភាពមិនអាចទទួលបានការដាក់ឲ្យចូលរៀនបណ្ដោះអាសន្នដើម្បីសុវត្ថិភាពបានទេ លុះត្រាតែមានកាលៈទេសៈពិសេស។ សូមអានផ្នែកបន្ទាប់ ដើម្បីស្វែងយល់បន្ថែមអំពីវិន័យសម្រាប់សិស្សដែលមានពិការភាព។

សិស្សដែលត្រូវបានបញ្ជូនទៅទទួលសវនាការវិន័យទទួលបាននីតិវិធីត្រឹមត្រូវពេញលេញ ដើម្បីកំណត់ថាតើសិស្សគួរតែត្រូវបានបណ្ដេញចេញពីសាលាបច្ចុប្បន្នរបស់ពួកគេដែរឬទេ។ សវនាការវិន័យត្រូវបានធ្វើឡើងដោយអ្នកទំនាក់ទំនងផ្នែកវិន័យស្ដារនីតិសម្បទាឥតលម្អៀង។

សិស្ស និងមាតាបិតា/អាណាព្យាបាលដែលចូលរួមក្នុងនីតិវិធីសវនាការវិន័យមានសិទ្ធិដូចខាងក្រោម៖

- ពិនិត្យភស្តុតាងណាមួយដែលសាលាគ្រោងនឹងបង្ហាញនៅក្នុងសវនាការ។
- មានអ្នកបកប្រែផ្ទាល់មាត់ជាភាសាដែលគេចង់បាន។
- នាំសាក្សីផ្ទាល់ខ្លួន និង/ឬលិខិតបញ្ជាក់អត្តចរិតរបស់ពួកគេទៅសវនាការ។
- នាំអ្នកតំណាង និង/ឬអ្នកតស៊ូមតិទៅសវនាការ។
- ទទួលបានឱកាសពីរក្នុងការចូលរួមសវនាការ។
- សួរសំណួររបស់សាលា និងបង្ហាញភស្តុតាងប្រសិនបើវាទាក់ទងនឹងឧប្បត្តិហេតុ។
- ទទួលបានសេចក្ដីសម្រេចលើសវនាការក្នុងរយៈពេល 7 ថ្ងៃនៃសវនាការ។
- ទទួលបានច្បាប់ចម្លងស្ដីពីកំណត់ត្រាសវនាការ ប្រសិនបើមានការស្នើសុំ។
- ទទួលបានច្បាប់ចម្លងស្ដីពីកំណត់ត្រាសិស្សរបស់ពួកគេ ប្រសិនបើមានការស្នើសុំ។

<u>សេចក្ដីសម្រេចរបស់ សវនាការ</u>

អ្នកទំនាក់ទំនងផ្នែកវិន័យស្ដារនីតិសម្បទាឥតលម្អៀងនឹងពិចារណាលើភស្តុតាង ការសន្ទនានៅក្នុងសវនាការ និងកំណត់ត្រាអំពីការសិក្សា អាកប្បកិរិយា និងវត្តមានរបស់សិស្សទាំងអស់ នៅពេលធ្វើការសម្រេចចិត្តលើលទ្ធផល។

លទ្ធផលអាចរួមបញ្ចូលមួយក្នុងចំណោមដូចខាងក្រោម៖
- សិស្សនៅតែស្ថិតក្នុងសាលាបច្ចុប្បន្នរបស់ពួកគេ ដោយសារមានភស្តុតាងមិនគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីការរំលោភលើក្រមសីលធម៌។
- សិស្សនៅតែស្ថិតក្នុងសាលាបច្ចុប្បន្នរបស់ពួកគេដោយធ្វើកិច្ចសន្យាអាកប្បកិរិយា។
- សិស្សនៅតែស្ថិតក្នុងសាលាបច្ចុប្បន្នរបស់ពួកគេដោយមិនធ្វើកិច្ចសន្យាអាកប្បកិរិយា (ឧ. បានទទួលផលវិបាកគ្រប់គ្រាន់រួចហើយ)។
- សិស្សត្រូវបានផ្ទេរក្នុងលក្ខណៈដូចគ្នាទៅមណ្ឌលសិក្សាធិការមួយផ្សេងទៀត ឬសាលាដែលប្រតិបត្តិការតាមកិច្ចសន្យា។
- សិស្សត្រូវបានផ្ទេរទៅកម្មវិធីអន្តរកាល AEDY។

ការអប់រំជំនួសសម្រាប់យុវជនដែលរំខាន (AEDY)
- កម្មវិធីអន្តរកាល AEDY របស់រដ្ឋ Pennsylvania ផ្តល់ការគាំទ្រដល់សិស្សថ្នាក់ទី 6-12 ដែលត្រូវបានបណ្តេញចេញពីការអប់រំចំណេះទូទៅសម្រាប់ហេតុផលដាក់វិន័យ។
  - សិស្សត្រូវតែមានសវនាការមុនពេលដាក់ឲ្យចូលរៀន លើកលែងតែការដាក់ឲ្យចូលរៀនបណ្តោះអាសន្ន ដើម្បីសុវត្ថិភាពសមទទួលបានដោយសារតែស្ថានភាពធ្ងន់ធ្ងរ។
- AEDY ផ្តល់នូវការរួមបញ្ចូលគ្នានៃការបង្រៀនការសិក្សាជាបុគ្គល និងការប្រឹក្សាអំពីការកែប្រែអាកប្បកិរិយាក្នុងបរិបទជំនួសដែលខ្លាំងជាងនេះ ដើម្បីជួយសិស្សវិលត្រលប់មកសាលាអប់រំចំណេះទូទៅវិញដោយជោគជ័យ។
- មណ្ឌលសិក្សាធិការ និងកម្មវិធីអន្តរកាល AEDY ធ្វើការជាមួយក្រុមគ្រួសារដើម្បីបង្កើតគោលដៅអាកប្បកិរិយាដោយផ្អែកលើហេតុផលរបស់ពួកគេសម្រាប់ការដាក់ឲ្យចូលរៀន និងការវាយតម្លៃ។
  - សិស្សទទួលបានការពិនិត្យតាមកាលកំណត់ជាផ្លូវការ (ការពិនិត្យវឌ្ឍនភាព) មុនកាលបរិច្ឆេទចាកចេញដោយសន្មត។
  - នៅពេលដែលសម្រេចបានគោលដៅអាកប្បកិរិយាហើយ សិស្សរៀបចំការផ្លាស់ប្តូរទៅកាន់បរិបទអប់រំចំណេះទូទៅជាមួយនឹងផែនការផ្លាស់ប្តូរ។
- ការដាក់ឲ្យចូលរៀននៅក្នុងកម្មវិធីអន្តរកាល AEDY គឺជាការដាក់ឲ្យចូលរៀនបណ្តោះអាសន្ន សិស្សអាចនៅបន្តរហូតដល់ពួកគេបានសម្រេចគោលដៅអាកប្បកិរិយារបស់ពួកគេ ឬលុះត្រាតែត្រូវបានបណ្តេញចេញ។
- អ្នកសិក្សាភាសាអង់គ្លេស (EL) និងសិស្សដែលមានផែនការអប់រំបុគ្គល (IEP) មិនអាចត្រូវបានដាក់នៅកម្មវិធីអន្តរកាល AEDY ដែលមិនអាចបំពេញតាមតម្រូវការនៃការបង្រៀនរបស់ពួកគេបានទេ។ កម្មវិធីអន្តរកាល AEDY របស់មណ្ឌលសិក្សាធិការដែលមានឈ្មោះថា Achieve Academy មានសិទ្ធិបដិសេធការចូលសាលា ប្រសិនបើពួកគេមិនអាចមានកម្មវិធីគ្រប់គ្រាន់សម្រាប់សិស្ស។

# វិន័យសម្រាប់សិស្សដែលមានពិការភាព

សិស្សដែលមានពិការភាពអាចទទួលបានវិន័យស្របតាមក្រមសីលធម៌ស។ ពួកគេក៏ត្រូវតែទទួលបានការអប់រំសាធារណៈឥតគិតថ្លៃ និងសមស្រប (FAPE) ផងដែរ។ សាលាត្រូវតែប្រកាន់ខ្ជាប់នូវបទប្បញ្ញត្តិទាំងអស់ដែលមានចែងនៅក្រោមច្បាប់ស្តីពីជនពិការ (IDEA)។

## ការព្យួរការសិក្សា
គោលការណ៍ណែនាំអំពីការព្យួរការសិក្សាដែលមានចែងខាងលើអនុវត្តចំពោះសិស្សទាំងអស់ រួមទាំងជនមានពិការភាពផងដែរ។ លើសពីនេះទៀត ត្រូវតែអនុវត្តតាមបទប្បញ្ញត្តិខាងក្រោម៖

សិស្សដែលត្រូវបានកំណត់ថាមានពិការភាពផ្នែកបញ្ញា
សិស្សដែលត្រូវបានកំណត់ថាមានពិការភាពផ្នែកបញ្ញាអាចត្រូវបានដកចេញពីអគារសិក្សាបានលុះត្រាតែមានការព្យួរការសិក្សា ឬសវនាការវិន័យ ប្រសិនបើមានកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរពីមាតាបិតា/អាណាព្យាបាល ឬការយល់ព្រមជាលាយលក្ខណ៍អក្សរពីការិយាល័យអប់រំពិសេសនៃនាយកដ្ឋានអប់រំរដ្ឋ Pennsylvania (PDE)។ អាចទាក់ទង PDE ដោយហៅទៅលេខ 717-783-6913។

សិស្សផ្សេងទៀតទាំងអស់ដែលទទួលបាន សេវាកម្មអប់រំពិសេស ឬផែនការ 504
មណ្ឌលសិក្សាធិការអាចព្យួរការសិក្សារបស់សិស្សដែលកំពុងទទួលបានសេវាកម្មអប់រំពិសេសរហូតដល់ដប់ (10) ថ្ងៃសិក្សាជាប់ៗគ្នា ឬដប់ប្រាំ (15) ថ្ងៃសិក្សាជាប់ៗគ្នាក្នុងមួយឆ្នាំសិក្សាដោយមិនផ្តល់សេវាកម្មអប់រំពិសេសដូចមានចែងក្នុងផែនការ IEP របស់ពួកគេ។

## នីតិវិធីកំណត់ពិការភាព
ការប្រជុំកំណត់ពិការភាពត្រូវតែធ្វើឡើងនៅពេលណាដែលមានការផ្លាស់ប្តូរកន្លែងរៀន។ សម្រាប់សិស្សដែលត្រូវបានកំណត់ថាមានពិការភាពផ្នែកបញ្ញា ការព្យួរការសិក្សាមួយ (1) ថ្ងៃត្រូវបានចាត់ទុកថាជាការផ្លាស់ប្តូរកន្លែងរៀន។ សម្រាប់សិស្សទាំងអស់ផ្សេងទៀតដែលមានពិការភាព ការផ្លាស់ប្តូរកន្លែងរៀនត្រូវបានចាត់ទុកថាជាការព្យួរការសិក្សារយៈពេលដប់ (10) ថ្ងៃជាប់ៗគ្នា ដប់ប្រាំ (15) ថ្ងៃជាប់ៗគ្នា ដែលជាស៊េរីនៃការដកចេញដែលបង្កើតជាគំរូនៃការបណ្តេញចេញ និង/ឬការផ្ទេរជាការដាក់វិន័យ។

គោលបំណងនៃកិច្ចប្រជុំកំណត់ពិការភាពគឺដើម្បីឆ្លើយសំណួរចំនួនពីរ៖

1. តើទង្វើនេះបណ្តាលមកពី ឬតើវាមានទំនាក់ទំនងផ្ទាល់ និងសំខាន់ចំពោះពិការភាពរបស់សិស្សដែរឬទេ?
2. តើទង្វើនេះគឺជាលទ្ធផលផ្ទាល់នៃការបរាជ័យរបស់សាលាក្នុងការអនុវត្តផែនការ IEP របស់សិស្សដែរឬទេ?

ប្រសិនបើអាកប្បកិរិយាមិនត្រូវបានចាត់ទុកថាជាការបង្ហាញសញ្ញានៃពិការភាពរបស់សិស្សទេ សាលាអាចបន្តចំណាត់ការវិន័យដែលបានណែនាំដោយអនុលោមតាមក្រមសីលធម៌។ ប្រសិនបើអាកប្បកិរិយាត្រូវបានចាត់ទុកថាជាការបង្ហាញសញ្ញានៃពិការភាពរបស់សិស្ស ការផ្លាស់ប្តូរកន្លែងរៀនដែលបានស្នើឡើងអាចមិនត្រូវបានអនុញ្ញាតទេ។

គោលការណ៍ណែនាំខាងក្រោមអនុវត្តចំពោះនីតិវិធីកំណត់ពិការភាព៖

- ផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់មាតាបិតា/អាណាព្យាបាលអំពីចំណាត់ការវិន័យដែលបានណែនាំ និងការអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំកំណត់ពិការភាពជាមួយក្រុមការងារ IEP របស់សិស្ស។
  - កិច្ចប្រជុំនេះត្រូវតែធ្វើឡើងក្នុងរយៈពេល 10 ថ្ងៃគិតចាប់ពីពេលដែលឧប្បត្តិហេតុកើតឡើង។
  - ក្នុងអំឡុងពេលកិច្ចប្រជុំ ការវាយតម្លៃថ្មីៗបំផុតរបស់សិស្ស IEP និងការដាក់ឲ្យចូលរៀននឹងត្រូវបានពិនិត្យ ព្រមទាំងព័ត៌មានលម្អិតនៃឧប្បត្តិហេតុដែលនាំទៅដល់ការដាក់វិន័យដែលបានស្នើឡើង។
  - ការកំណត់ពិការភាពដែលបានបញ្ចប់ត្រូវតែចុះហត្ថលេខាដោយមាតាបិតា/អាណាព្យាបាល និងក្រុមការងារ IEP រួមទាំងចិត្តវិទូសាលាផងដែរ។
- ចេញសេចក្តីជូនដំណឹងអំពីការដាក់ក្នុងសាលាអប់រំដែលបានណែនាំ (NOREP) ជាមួយនឹងលទ្ធផលនៃការកំណត់ និងច្បាប់ចម្លងនៃសេចក្តីជូនដំណឹងអំពីការការពារសុវត្ថិភាពតាមនីតិវិធី (PSN) ជូនមាតាបិតា/អាណាព្យាបាល។
  - ប្រសិនបើមាតាបិតា/អាណាព្យាបាលមិនយល់ស្របនឹងការសម្រេចចិត្តដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំកំណត់ពិការភាពនេះទេ ពួកគេអាចស្នើសុំសវនាការពន្លឿនការអប់រំពិសេសមួយ ហើយមន្ត្រីសវនាការដែលតែងតាំងដោយរដ្ឋនឹងពិនិត្យការកំណត់ពិការភាពនេះ។ ការណែនាំអំពីការស្នើសុំសវនាការអាចត្រូវបានរកឃើញនៅក្នុង NOREP ហើយត្រូវតែបញ្ចប់ក្នុងរយៈពេលដប់ (10) ថ្ងៃ។

ត្រូវប្រាកដថា ផែនការ IEP មានការអនុលោមតាមច្បាប់ ក៏ដូចជាឯកសារពាក់ព័ន្ធផ្សេងទៀត ប្រសិនបើមាន។ ឧទាហរណ៍ ការវាយតម្លៃអាកប្បកិរិយាមុខងារ (FBA) ឬផែនការគាំទ្រអាកប្បកិរិយាវិជ្ជមាន (PBSP) ប្រហែលជាត្រូវការដោយអនុលោមតាមផែនការ IEP។

### ការដាក់ឲ្យចូលរៀនបណ្តោះអាសន្ន 45 ថ្ងៃ

សាលាអាចស្នើសុំការដាក់ឲ្យចូលរៀនបណ្តោះអាសន្នរយៈពេល 45 ថ្ងៃដោយមិនគិតពីលទ្ធផលនៃការកំណត់ពិការភាព ប្រសិនបើឧប្បត្តិហេតុពាក់ព័ន្ធនឹងកាលៈទេសៈពិសេសមួយក្នុងចំណោម (3) កាលៈទេសៈពិសេសនៅក្រោមច្បាប់ IDEA៖

- កាន់កាប់ ឬប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ឬលក់ ឬដើរពពាយនាយលក់សារធាតុញៀនដោយចេតនា ពេលនៅសាលារៀន លើបរិវេណសាលា ឬនៅកម្មវិធីសាលា។
- យកអាវុធទៅ ឬកាន់អាវុធនៅសាលា លើបរិវេណសាលា ឬនៅកម្មវិធីសាលា។
  - យោងតាមច្បាប់ IDEA អាវុធត្រូវបានកំណត់និយមន័យថាជាប្រដាប់ ឧបករណ៍ សម្ភារៈ ឬសារធាតុដែលមានចលនា ឬមិនមានចលនា ដែលប្រើសម្រាប់ ឬមានសមត្ថភាពអាចបង្កឱ្យមនុស្សស្លាប់ ឬរបួសធ្ងន់ធ្ងរ។
  - នេះមិនរាប់បញ្ចូលកូនកាំបិតដែលមានផ្លែកាំបិតប្រវែងតិចជាង 2½ អ៊ីញ ឬវត្ថុធម្មតាដែលមិនត្រូវបានផលិតឡើងដើម្បីធ្វើជាអាវុធ។
- បានបង្កស្នាមរបួសរាងកាយធ្ងន់ធ្ងរ (SBI) លើមនុស្សម្នាក់ទៀតពេលនៅសាលារៀន លើបរិវេណសាលា ឬនៅកម្មវិធីសាលា។
  - យោងតាមច្បាប់ IDEA របួសរាងកាយធ្ងន់ធ្ងរត្រូវបានកំណត់និយមន័យថាជាហានិភ័យចម្បងនៃការស្លាប់ ការឈឺចាប់រាងកាយខ្លាំង ការខូចរូបរាងរយៈពេលយូរ និងជាក់ស្តែង ឬការបាត់បង់រយៈពេលយូរ ឬការចុះខ្សោយមុខងារណាមួយនៃអវៈយវៈរាងកាយ សរីរាង្គ ឬញាណសតិ។ SBI ត្រូវតែបញ្ជាក់បន្ថែមដោយភស្តុតាង។

គោលបំណងនៃការដាក់ឲ្យចូលរៀនបណ្តោះអាសន្នរយៈពេល 45 ថ្ងៃគឺដើម្បីឱ្យសិស្សទទួលបានអន្តរាគមន៍នៅក្នុងបរិបទ AEDY ខណៈពេលដែលក្រុមការងារ IEP របស់សាលាបញ្ជូនមកធ្វើការវាយតម្លៃឡើងវិញនូវការរៀបចំកម្មវិធីឲ្យ និងការដាក់សិស្សក្នុងសាលា។ ការដាក់ឲ្យចូលរៀនបណ្តោះអាសន្ន 45 ថ្ងៃអាចមិនលើសពី 45 ថ្ងៃបានទេ។

ប្រសិនបើអាកប្បកិរិយារបស់សិស្សមិនមែនជាកាលៈទេសៈពិសេសមួយក្នុងចំណោមបី (3) កាលៈទេសៈនោះទេ វាគឺជាសញ្ញានៃពិការភាពរបស់សិស្ស ហើយសិស្សទំនងជាបង្កស្នាមរបួសដល់ខ្លួនឯង ឬអ្នកដ៏ទៃ ដូច្នេះថ្នាក់ដឹកនាំសាលាអាចស្នើសុំសវនាការពន្លឿនដែលធ្វើឡើងដោយមន្ត្រីសវនាការអប់រំពិសេសបាន ដើម្បីទទួលបានការដាក់ឲ្យចូលរៀន 45 ថ្ងៃ។ សំណើនេះអាចធ្វើទៅការិយាល័យប្រឹក្សាទូទៅ។

# នីតិវិធីបណ្តេញចេញ

យោងតាមច្បាប់រដ្ឋ Pennsylvania ការបណ្តេញចេញត្រូវបានកំណត់និយមន័យថាជាការបណ្តេញចេញពីសាលារៀន និងសកម្មភាពសាលាណាមួយលើសពីដប់ (10) ថ្ងៃសិក្សា។ សិស្សដែលបានប្រព្រឹត្តបទល្មើសដែលរងការបណ្តេញចេញ អាចត្រូវបានបញ្ជូនទៅទទួលសវនាការវិន័យក្រៅផ្លូវការ និងការដាក់ AEDY នៅចំណុចនោះ គេនឹងកំណត់ថាតើសិស្សគួរត្រូវបានណែនាំសម្រាប់បណ្តេញចេញជាផ្លូវការឬអត់។

នីតិវិធីសវនាការលើការបណ្តេញចេញជាផ្លូវការរួមមានលក្ខខណ្ឌតម្រូវនីតិវិធីត្រឹមត្រូវដូចខាងក្រោម៖

- ការជូនដំណឹងអំពីការល្មើសជាលាយលក្ខណ៍អក្សរតាមសំបុត្របញ្ជាក់ទៅកាន់មាតាបិតា/អាណាព្យាបាលជាភាសាដែលគេចង់បាន។
- យ៉ាងហោចណាស់បី (3) ថ្ងៃជូនដំណឹងអំពីពេលវេលា និងទីកន្លែងនៃសវនាការ ដែលរួមមានច្បាប់ចម្លងនៃគោលនយោបាយអំពីការបណ្តេញចេញ នីតិវិធីសវនាការ និងការជូនដំណឹងអំពីសិទ្ធិធ្វើតំណាងដោយមេធាវី។
- សិស្សអាចនឹងស្នើសុំកំណត់ពេលសវនាការឡើងវិញ នៅពេលដែលពួកគេបង្ហាញពីមូលហេតុល្អនៃការពន្យារពេល។
- សវនាការនឹងមានលក្ខណៈឯកជន លុះត្រាតែសិស្ស ឬមាតាបិតា/អាណាព្យាបាលស្នើសុំសវនាការជាសាធារណៈ។
- តំណាងដោយមេធាវី ជាបន្ទុកចំណាយរបស់មាតាបិតា/អាណាព្យាបាល។
- មាតាបិតា/អាណាព្យាបាលអាចចូលរួមសវនាការ។
- ការបញ្ចេញឈ្មោះសាក្សីប្រឆាំងនឹងសិស្ស និងច្បាប់ចម្លងនៃចម្លើយជាលាយលក្ខណ៍អក្សរ ឬលិខិតបញ្ជាក់របស់ពួកគេ។
- សិទ្ធិស្នើសុំឱ្យសាក្សីប្រឆាំងនឹងសិស្សបង្ហាញខ្លួនដោយផ្ទាល់ និងឆ្លើយសំណួរ ឬត្រូវបានសួរចម្លើយ។
- សិទ្ធិផ្តល់សក្ខីកម្ម បង្កើតអំណះអំណាង និងបង្ហាញសាក្សីតាងនាមឲ្យសិស្ស។
- កំណត់ត្រាជាលាយលក្ខណ៍អក្សរ ឬជាសំឡេងនៃសវនាការត្រូវរក្សាទុក ហើយច្បាប់ថតចម្លងមានផ្តល់ជូនសិស្សជាបន្ទុកចំណាយរបស់សិស្ស ឬដោយមិនគិតថ្លៃប្រសិនបើជាសិស្សក្រីក្រ។
    - សវនាការត្រូវធ្វើឡើងក្នុងរយៈពេល 15 ថ្ងៃសិក្សាគិតចាប់ពីថ្ងៃជូនដំណឹងអំពីការចោទប្រកាន់ លើកលែងតែការពន្យារពេលត្រូវបានយល់ព្រមដោយភាគីទាំងពីរ ឬត្រូវពន្យារពេលដោយ៖
    - តម្រូវការរបាយការណ៍មន្ទីរពិសោធន៍ពីទីភ្នាក់ងារអនុវត្តច្បាប់ ឬ
    - កំពុងរង់ចាំការវាយតម្លៃ ឬនីតិវិធីតុលាការ ឬនីតិវិធីរដ្ឋបាលផ្សេងទៀត ដោយសារសិស្សប្រើប្រាស់សិទ្ធិរបស់ខ្លួនក្រោមច្បាប់ស្តីពីការអប់រំជនពិការ (IDEA) ឬ
    - ការពន្យារពេលគឺចាំបាច់ដោយសារតែលក្ខខណ្ឌ ឬឧត្តមប្រយោជន៍របស់ជនរងគ្រោះ ក្នុងករណីតុលាការអនីតិជន ឬតុលារព្រហ្មទណ្ឌពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ ឬរបួសរាងកាយធ្ងន់ធ្ងរ។
- សេចក្តីជូនដំណឹងអំពីសិទ្ធិក្នុងការប្តឹងតវ៉ានឹងលទ្ធផលនៃសវនាការត្រូវតែផ្តល់ជូនដល់សិស្ស និងមាតាបិតា/អាណាព្យាបាលនូវសេចក្តីសម្រេចចិត្តបណ្តេញចេញជាភាសាដែលពួកគេចង់បាន។

ប្រសិនបើសិស្សម្នាក់ត្រូវបានបណ្តេញចេញដោយគណៈកម្មការសាលា មាតាបិតា/អាណាព្យាបាលរបស់សិស្សមានពេល 30 ថ្ងៃ ដើម្បីផ្តល់ឯកសារជាលាយលក្ខណ៍អក្សរដែលបញ្ជាក់ថាសិស្សស្ថិតនៅក្នុងកម្មវិធីអប់រំផ្សេងទៀត។ ប្រសិនបើពួកគេមិនអាចស្វែងរកកម្មវិធីអប់រំជំនួសបានទេ មណ្ឌលសិក្សាធិការនឹងផ្តល់ការអប់រំដល់សិស្ស។ សិស្សដែលត្រូវបានបណ្តេញចេញពីមណ្ឌលសិក្សាធិការជាអចិន្ត្រៃយ៍ដោយសំឡេងឆ្នោតវិជ្ជមានភាគច្រើននៃគណៈកម្មការសាលាអាចដាក់ពាក្យសុំការអនុញ្ញាតចូលរៀនវិញបាន។ គណៈកម្មការសាលាប្រគល់សិទ្ធិអំណាចសម្រាប់ការសម្រេចចិត្តអនុញ្ញាតឲ្យចូលរៀនវិញទាំងអស់ទៅប្រធាននាយក ឬអ្នកតំណាងរបស់ប្រធាននាយក។ សិស្សដែលត្រូវបានបណ្តេញចេញជាបណ្តោះអាសន្ន មិនចាំបាច់ដាក់ពាក្យសុំអនុញ្ញាតចូលរៀនវិញទេ ពីព្រោះពួកគេត្រូវបានអនុញ្ញាតឲ្យចូលរៀននៅមណ្ឌលសិក្សាធិការវិញដោយស្វ័យប្រវត្តិនៅពេលចប់រយៈពេលនៃការបណ្តេញចេញ។ សេចក្តីសម្រេចអនុញ្ញាតឲ្យចូលរៀនវិញគឺជាសេចក្តីសម្រេចស្ថាពរ ហើយមិនត្រូវពិនិត្យឡើងវិញដោយប្តឹងតវ៉ាទៅគណៈកម្មការ ឬតុលាការឡើយ។

# ការបញ្ជូនទៅនាយកដ្ឋានប៉ូលិសក្រុង Philadelphia

បទល្មើសអាកប្បកិរិយាមួយចំនួននៅក្នុងក្រមសីលធម៌ក៏ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មផងដែរ យោងទៅតាមច្បាប់រដ្ឋ Pennsylvania។ មណ្ឌលសិក្សាធិការមានអនុស្សរណៈនៃការយោគយល់គ្នា (MOU) ជាមួយនាយកដ្ឋានប៉ូលិសក្រុង Philadelphia (PPD)។
MOU បានបញ្ជាក់យ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មខាងក្រោមត្រូវតែរាយការណ៍៖ ការចាប់ពង្រត់ និងការប៉ុនប៉ង ការវាយដំ ការបន្លាចបំផ្ទុះគ្រាប់បែក ការគាស់ចូលលួច បទល្មើសគ្រឿងញៀន និងគ្រឿងស្រវឹង ការប្រកាសអាសន្នអំពីអគ្គិភ័យ និងការប្រកាសអាសន្នមិនពិត (ការបង្កអគ្គិភ័យ) ការគូរគំនូរនៅទីកន្លែងសាធារណៈ (ប្រសិនបើមានលក្ខណៈប្រកាន់ជាតិសាសន៍ ឬគំរាមកំហែង) ការរំលោភបំពានលើកុមារ ឧក្រិដ្ឋកម្មស្អប់ខ្ពើម បទល្មើសសីលធម៌ (មានលក្ខណៈផ្លូវភេទ) ការបំផ្លាញទ្រព្យសម្បត្តិ ការប្លន់ ការលួច ការចូលដោយគ្មានការអនុញ្ញាត និងបទល្មើសអាវុធ។

សិស្សដែលមានអាយុដប់មួយ (11) ឆ្នាំ និងក្មេងជាងនេះនឹងមិនត្រូវបានចាប់ខ្លួនទេ លុះត្រាតែពួកគេបានប្រព្រឹត្តបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋដែលបានរាប់បញ្ចូលក្នុងបញ្ជីក្នុងអនុស្សរណៈនៃការយោគយល់។ មាតាបិតា/អាណាព្យាបាលរបស់ជនរងគ្រោះ និងសិស្សគួរតែត្រូវបានទាក់ទងភ្លាមៗអំពីការចូលរួមពាក់ព័ន្ធរបស់កូនរបស់ពួកគេ ហើយការព្យាយាមទាក់ទងមាតាបិតាគួរតែត្រូវបានកត់ត្រាទុកជាឯកសារ។

មណ្ឌលសិក្សាធិការក៏មានអនុស្សរណៈយោគយល់គ្នាទាក់ទងនឹងកម្មវិធីបង្វែរជាមួយ PPD ផងដែរ។ កម្មវិធីបង្វែរអនុញ្ញាតឱ្យ PPD បង្វែរសិស្សពីការចាប់ខ្លួនប្រសិនបើសិស្សនោះបានប្រព្រឹត្តបទល្មើសអហិង្សានៅក្នុងសាលា ហើយមិនធ្លាប់មានប្រវត្តិចាប់ខ្លួនពីមុនមក។ ក្នុងករណីទាំងនោះ សិស្សនឹងទទួលបានសេវាកម្មពីនាយកដ្ឋានសេវាមនុស្ស។

**នីតិវិធីរាយការណ៍របស់សាលា**

នៅក្នុងបណ្តាសាលាដែលមានមន្ត្រីសុវត្ថិភាពសាលា (SSO) នៅពេលដែលមានឧប្បត្តិហេតុកើតឡើងដែលអាចជាបទឧក្រិដ្ឋ ថ្នាក់ដឹកនាំសាលាគួរតែជូនដំណឹងដល់ SSO មុននឹងធ្វើការបញ្ជូនទៅកាន់ប៉ូលិសដើម្បីអាចចាប់ខ្លួនសិស្ស។ បុគ្គលិកសុវត្ថិភាពសាលាទាំងអស់បានទទួលការបណ្តុះបណ្តាលលើកម្មវិធីបង្វែរនៃសាលាប៉ូលិសក្រុង Philadelphia។ SSO នឹងទាក់ទងកម្មវិធីបង្វែរ PPD តាមលេខ 215-400-5526/215-400-5530 ដើម្បីកំណត់ថាតើបទល្មើសនេះមានសិទ្ធិបង្វែរដែរឬទេ។ បទល្មើសដែលមិនមានសិទ្ធិបង្វែរនឹងត្រូវបញ្ជូនទៅនាយកដ្ឋានប៉ូលិសក្រុង Philadelphia។ បណ្តាសាលាដែលគ្មានមន្ត្រីសុវត្ថិភាពត្រូវបានណែនាំឱ្យទាក់ទងផ្ទាល់ទៅ PPD និងអ្នកគ្រប់គ្រងតំបន់សុវត្ថិភាពសាលារបស់ពួកគេ។

# ឧបសម្ព័ន្ធ - ម៉ាទ្រីសអាកប្បកិរិយា

ម៉ាទ្រីសអាកប្បកិរិយាខាងក្រោមរួមមាន បញ្ជីអាកប្បកិរិយា ឬក្រមសីលធម៌ "ការបំពាន" លេខក្បួនច្បាប់ និងនិយមន័យដែលត្រូវគ្នាសម្រាប់ឱ្យសាលារៀនជ្រើសរើសអាកប្បកិរិយាដែលសមស្របនៅពេលបំពេញបែបបទបញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ (ODR) និងពេលដោះស្រាយឧប្បត្តិហេតុ។ កម្រិតថ្នាក់បង្ហាញពីការឆ្លើយតបដែលអាចអនុវត្តបានចំពោះថ្នាក់នីមួយៗ។ ឧទាហរណ៍ មានតែថ្នាក់ទី 3-12 ប៉ុណ្ណោះទើបអាចត្រូវព្យួរការសិក្សាក្រៅសាលា ហើយមានតែថ្នាក់ទី 6-12 ប៉ុណ្ណោះទើបអាចទទួលសវនាការវិន័យ និង/ឬការបណ្ដេញចេញបាន។ ទោះជាយ៉ាងនេះក្តី វាពុំមានន័យថា សាលាត្រូវតែចេញការឆ្លើយតបបែបនោះ ដោយសារតែអាកប្បកិរិយាមានលក្ខណៈត្រូវរងការព្យួរការសិក្សា ឬរងសវនាការវិន័យនោះទេ។ "មិនអនុវត្ត" បង្ហាញថា ការឆ្លើយតបមិនអាចអនុវត្តបានទេ។

| # | និយមន័យអាកប្បកិរិយា | ការឆ្លើយតបផ្អែកតាមសាលារៀនតែប៉ុណ្ណោះ | ការព្យួរការសិក្សារយៈពេលខ្លី ថ្នាក់ទី 3-12 1-3 ថ្ងៃ | ការព្យួរការសិក្សារយៈពេលវែង ថ្នាក់ទី 3-12 4-10 ថ្ងៃ | ការបញ្ជូនទៅកាន់សវនាការវិន័យ ថ្នាក់ទី 6-12 | ការបណ្ដេញចេញ ថ្នាក់ទី 6-12 |
|---|---|---|---|---|---|---|
| **អាកប្បកិរិយាក្រោមការគ្រប់គ្រងនៃថ្នាក់រៀន - អនីតិជន** | | | | | | |
| 1 | **កាយវិការ/ភាសាអាសគ្រាម និងការហៅឈ្មោះ។** សិស្សដែលជេរ ឬប្រើកាយវិការ/ភាសាអាសអាភាសទៅកាន់សមាជិកសហគមន៍ផ្សេងទៀត។<br><br>ការហៅឈ្មោះរួមមាន៖<br>• ការហៅឈ្មោះសមាជិកសហគមន៍ផ្សេងទៀតខុសពីឈ្មោះដែលគេពេញចិត្ត<br>• ការបញ្ចេញមតិដែលគេយល់ឃើញថាមានគ្រោះថ្នាក់ ប៉ុន្តែមិនទាន់ត្រូវនឹងនិយមន័យរបស់មណ្ឌលសិក្សាធិការអំពីការប្រមាថ | **ថ្នាក់មត្តេយ្យ-ទី 12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 2 | **អាកប្បកិរិយារំខានក្នុងថ្នាក់រៀន។** សិស្សដែលរំខានបរិយាកាសសិក្សាដោយចេតនាដោយមិនធ្វើតាមការរំពឹងទុក ដែល បានផ្តល់ជាការប្រាប់ឡើងវិញទាំងជាពាក្យសម្តី និងមិនមែនពាក្យសម្តី។<br><br>អាកប្បកិរិយារំខានរួមមាន៖<br>• ចេញពីកន្លែងអង្គុយដែលបានកំណត់ដោយគ្មានការអនុញ្ញាត<br>• និយាយនៅពេលមិនគួរបញ្ចេញសំឡេង<br>• ប្រើទូរសព្ទក្នុងថ្នាក់រៀនដោយគ្មានការអនុញ្ញាត<br>• មិនប្រកាន់ខ្ជាប់បទដ្ឋានថ្នាក់រៀនដែលបានបិទផ្សាយ និង/ឬ<br>• វាយគ្នាលេង | **ថ្នាក់មត្តេយ្យ-ទី 12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 3 | **ការបោកប្រាស់។** សិស្សដែលដាក់ ឬមានបំណងដាក់កិច្ចការដែលមិនមែនជារបស់ខ្លួន រួមទាំងការលួចចម្លង។ | **ថ្នាក់មត្តេយ្យ-ទី 12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 4 | **ការគេច/ការមិនចូលថ្នាក់រៀន** សិស្សដែលមិនចូលរៀនជាទៀងទាត់ (ប្រចាំសប្តាហ៍ ប្រចាំថ្ងៃ) ដោយចេតនា ដែលប៉ះពាល់ដល់ការសិក្សារបស់សិស្ស និងបរិយាកាសរបស់សាលា។ ទង្វើនេះរួមមាន ការដើរនៅក្រៅថ្នាក់ ឬការគេចថ្នាក់រៀន/អគារសិក្សា។ | **ថ្នាក់មត្តេយ្យ-ទី 12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | Response does not apply | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **ការក្លែងបន្លំ - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| 5 | **ការបន្លំ/កែចំណាត់ថ្នាក់ កំណត់សម្គាល់សុំច្បាប់ ឬឯកសាររបស់សាលា។** សិស្សដែលចម្លងហត្ថលេខារបស់សិស្សដទៃដោយមានចេតនាកែកុនកំណត់ត្រាផ្លូវការរបស់សាលា ដូចជាចំណាត់ថ្នាក់ វត្តមាន ឬរបាយការណ៍នានាជាដើម។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |

| # | និយមន័យអាកប្បកិរិយា | ការឆ្លើយតបផ្អែកតាមសាលារៀនតែប៉ុណ្ណោះ | ការព្យួរការសិក្សារយៈពេលខ្លី ថ្នាក់ទី 3-12 1-3 ថ្ងៃ | ការព្យួរការសិក្សារយៈពេលវែង ថ្នាក់ទី 3-12 4-10 ថ្ងៃ | ការបញ្ជូនទៅកាន់សវនាការវិន័យ ថ្នាក់ទី 6-12 | ការបណ្តេញចេញ ថ្នាក់ទី 6-12 |
|---|---|---|---|---|---|---|
| **ការប្រើទ្រព្យសម្បត្តិផ្ទាល់ខ្លួន/សាលារៀនមិនត្រឹមត្រូវ - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| 6 | **ការបំផ្លាញទ្រព្យសម្បត្តិ (តិចជាង $500)។** សិស្សដែលធ្វើឱ្យខូចខាត ឬធ្វើឱ្យបែកបាក់ទ្រព្យសម្បត្តិរបស់សាលា ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សមាជិកផ្សេងទៀតនៃសហគមន៍សាលារៀន។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 7 | **ការបំផ្លាញទ្រព្យសម្បត្តិ (ច្រើនជាង $500)។** សិស្សដែលធ្វើឱ្យខូចខាត ឬធ្វើឱ្យបែកបាក់ទ្រព្យសម្បត្តិរបស់សាលា ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សមាជិកផ្សេងទៀតនៃសហគមន៍សាលារៀន។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 8 | **ការលួច (តិចជាង $500)។** សិស្សដែលយកទ្រព្យសម្បត្តិរបស់សាលា ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សមាជិកផ្សេងទៀតនៃសហគមន៍សាលារៀន។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 9 | **ការលួច (លើសពី $500)។** សិស្សដែលយកទ្រព្យសម្បត្តិរបស់សាលា ឬទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សមាជិកផ្សេងទៀតនៃសហគមន៍សាលារៀន។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 10 | **ការប្លន់។** សិស្សដែលយក ឬប៉ុនប៉ងយកទ្រព្យសម្បត្តិរបស់សិស្សដទៃ ឬសមាជិកសហគមន៍សាលាផ្សេងទៀតដោយកម្លាំងបាយ ការគំរាមកំហែងប្រើកម្លាំងបាយ ឬតាមរយៈការធ្វើឱ្យជនរងគ្រោះមានការភ័យខ្លាច។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 11 | **ការចូលក្នុងបរិវេណសាលាដោយមិនមានការអនុញ្ញាត។** សិស្សដែលចូលក្នុងអគារសាលានៅពេលដែលគេមិនអនុញ្ញាត។ នេះរួមមាន៖ ការទៅរៀន/ទៅលេងសាលាអំឡុងពេលព្យួរការសិក្សា ឬឱ្យខ្លួនឯង ឬឱ្យអ្នកផ្សេងជាសិស្ស/មិនមែនជាសិស្សចូលទៅក្នុងសាលាដោយមិនចូលតាមទ្វាធំសម្រាប់ភ្ញៀវ។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **ការឈ្លានពានខាងរាយកាង បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| 12 | **ការវាយគ្នា។** សិស្សដែលចូលរួមដោយចេតនានៅក្នុងការវាយតប់មួយទល់នឹងមួយ។ នេះគឺជាការវាយតប់ ដែលមិនមានអ្នកចូលរួមណាម្នាក់ត្រូវបានកំណត់ថាជាជនរងគ្រោះ។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 13 | **ការវាយគ្នាជាក្រុម។** សិស្សដែលចូលរួមដោយចេតនានៅក្នុងការវាយតប់ជាមួយអ្នកចូលរួមដោយចេតនាច្រើននាក់។ នេះគឺជាការវាយតប់ ដែលមិនមានអ្នកចូលរួមណាម្នាក់ត្រូវបានកំណត់ថាជាជនរងគ្រោះ។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 14 | **ការវាយប្រហារជាក្រុម។** សិស្ស រួមជាមួយសមាជិកសហគមន៍ផ្សេងទៀត ដែលចូលរួមក្នុងការវាយប្រហារទល់នឹងសមាជិកសហគមន៍ម្នាក់ ឬច្រើននាក់។ នេះគឺជាឧប្បត្តិហេតុ ដែលគេអាចកំណត់អ្នកចូលរួមយ៉ាងច្បាស់ថា នរណាជាជនរងគ្រោះ នរណាជាជនល្មើស។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ***ថ្នាក់ទី 6-12** |
| 15 | **ការវាយប្រហារ។** សិស្សដែលវាយ ដាល់ ទាត់ ចាក់ ឬធ្វើបាបរាងកាយសមាជិកសហគមន៍សាលាតាមមធ្យោបាយណាមួយដោយចេតនា និងដោយមិនករករឿង។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| 16 | ***ការបង្ករបួសរាងកាយធ្ងន់ធ្ងរ។** សិស្សដែលចូលរួមដោយចេតនានៅក្នុងការប្រយុទ្ធគ្នា ឬការវាយប្រហារដែលបង្ករបួសរាងកាយដល់សមាជិកសហគមន៍ផ្សេងទៀត។ របួសរាងកាយរួមមាន ការខូចទ្រង់ទ្រាយធ្ងន់ធ្ងរជាអចិន្ត្រៃយ៍ ឬការចុះខ្សោយ ឬការបាត់បង់រយៈពេលយូរនៃមុខងារសរីរាង្គ ឬផ្នែកណាមួយនៃរាងកាយ។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | **ថ្នាក់ទី 6-12** |

| # | និយមន័យអាកប្បកិរិយា | **ការឆ្លើយតបផ្នែកតាមសាលារៀនតែប៉ុណ្ណោះ** | **ការព្យួរការសិក្សារយៈពេលខ្លី**<br>ថ្នាក់ទី 3-12<br>1-3 ថ្ងៃ | **ការព្យួរការសិក្សារយៈពេលវែង**<br>ថ្នាក់ទី 3-12<br>4-10 ថ្ងៃ | **ការបញ្ជូនទៅកាន់សវនាការវិន័យ**<br>ថ្នាក់ទី 6-12 | **ការបណ្ដេញចេញ**<br>ថ្នាក់ទី<br>6-12 |
|---|---|---|---|---|---|---|
| **ការឈ្លានពានខាងរាងកាយ - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **17** | **ការបង្កគ្រោះថ្នាក់ដោយប្រហែស។** សិស្សដែលធ្វើសកម្មភាពដែលបង្កើតជាហានិភ័យខ្លាំងក្លាដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សមាជិកសហគមន៍ណាម្នាក់។<br><br>ការបង្កគ្រោះថ្នាក់ដោយប្រហែសរួមមាន៖<br>• ការគប់វត្ថុឆ្លងបន្ទប់/ចេញពីបង្អួចដែលអាចបង្កគ្រោះថ្នាក់<br>• ការធ្វើឱ្យសមាជិកសហគមន៍រអិល/ដួលដោយចេតនា<br>• ការហៅ/ការទាក់ទាញសមាជិកសហគមន៍ដោយចេតនាដើម្បីញុះញង់ឱ្យកើតហិង្សា<br>• ការចូលរួមក្នុងការវាយគ្នា/ការឈ្លោះគ្នាដែលរាំងស្ទះចរាចរណ៍ និង/ឬបង្កើតហានិភ័យសុវត្ថិភាព<br>• ការចាំងពន្លឺ/ការប្រើកាំភ្លើងក្មេងលេងដែលមិនចាត់ទុកថាជាអាវុធ ប៉ុន្តែបង្កឱ្យមានការភ័យខ្លាច | **ថ្នាក់<br>មត្តេយ្យ-ទី 12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **អាកប្បកិរិយាផ្លូវភេទ ការប្រមាថ និងការបៀតបៀន - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **18** | **សកម្មភាពផ្លូវភេទដែលមានការព្រមព្រៀង។** សិស្សដែលចូលរួមក្នុងសកម្មភាពផ្លូវភេទដែលមានការព្រមព្រៀង។ | **ថ្នាក់<br>មត្តេយ្យ-ទី 12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 3-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **19** | **ការប៉ះឬស្ទាបមិនសមរម្យដែលគ្មានការព្រមព្រៀង។** សិស្សដែលចូលរួមធ្វើការប៉ះឬស្ទាបដែលគេមិនចង់ ឬការបញ្ចេញកេរខ្មាសរបស់ខ្លួនឯង ឬរបស់សមាជិកសហគមន៍សាលាផ្សេងទៀត។<br><br>រាល់ការស្ទាបរក ការចាប់ ឬការបញ្ចេញអង្គជាត (របស់ខ្លួនឯង ឬអ្នកផ្សេងទៀត) ត្រូវតែរាយការណ៍ទៅអ្នកសម្របសម្រួលនៃចំណងជើង IX ចំពោះការបៀតបៀនដែលអាចមាន។ | **ថ្នាក់<br>មត្តេយ្យ-ទី 12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **20** | **ការបៀតបៀន។** សិស្សដែលចូលរួមនៅក្នុងការប្រព្រឹត្តដែលគេមិនស្វាគមន៍តាមរយៈពាក្យសម្ដី <u>សំណេរ រូបគំនូរ ឬដោយផ្ទាល់</u> ទាក់ទងនឹងយេនឌ័រ អាយុ ជាតិសាសន៍ ពណ៌សម្បុរ និន្នាការផ្លូវភេទ ការបង្ហាញអត្តសញ្ញាណយេនឌ័រ ដើមកំណើតជាតិសាសន៍ សាសនា ពិការភាព ជំនាញភាសាអង់គ្លេស ស្ថានភាពសង្គមសេដ្ឋកិច្ច និង/ឬជំនឿនយោបាយ។<br><br>លក្ខណៈវិនិច្ឆយការបៀតបៀន៖<br>• ត្រូវតែទាក់ទងនឹងកម្រិតដែលត្រូវការពារ<br>• ត្រូវតែគិតថាមានលក្ខណៈធ្ងន់ធ្ងរ ជាប់លាប់ ឬរាលដាល<br>• មិនចាំបាច់ទាល់តែមានបំណងធ្វើបាប សំដៅទៅរកគោលដៅជាក់លាក់ ឬបង្កឧប្បត្តិហេតុម្ដងហើយម្ដងទៀតនោះទេ។ | **ថ្នាក់<br>មត្តេយ្យ-ទី 12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 6-12** | **ថ្នាក់<br>ទី 6-12** |
| **21** | **ការប្រមាថ/ការប្រមាថតាមអ៊ីនធឺណិត។** ការប្រមាថគឺជាការប្រព្រឹត្តធ្ងន់ធ្ងរ និងរាលដាលដែលត្រូវតែស្របតាមលក្ខណៈវិនិច្ឆ័យខាងក្រោម៖<br>• ម្ដងហើយម្ដងទៀត/ជាប់លាប់<br>• ដោយមានចេតនា<br>• រួមមាន អតុល្យភាពអំណាច<br><br>**ការប្រមាថតាមអ៊ីនធឺណិត** មានលក្ខណៈវិនិច្ឆ័យដូចគ្នាដែរ តែវាកើតឡើងតាមរយៈឧបករណ៍ទំនាក់ទំនងបែបអេឡិចត្រូនិក ដូចជា បណ្ដាញសង្គម អ៊ីមែល ការផ្ញើសារ សារជាអក្សរ សារធ្វីត (tweets) ជាដើម។ | **ថ្នាក់<br>មត្តេយ្យ-ទី 12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 3-12** | **ថ្នាក់<br>ទី 6-12** | **ថ្នាក់<br>ទី 6-12** |

| # | និយមន័យអាកប្បកិរិយា | ការឆ្លើយតបផ្អែកតាមសាលារៀនតែប៉ុណ្ណោះ | ការព្យួរការសិក្សារយៈពេលខ្លី ថ្នាក់ទី 3-12 1-3 ថ្ងៃ | ការព្យួរការសិក្សារយៈពេលវែង ថ្នាក់ទី 3-12 4-10 ថ្ងៃ | ការបញ្ជូនទៅកាន់សវនាការវិន័យ ថ្នាក់ទី 6-12 | ការបណ្តេញចេញ ថ្នាក់ទី 6-12 |
|---|---|---|---|---|---|---|
| **អាកប្បកិរិយាផ្លូវភេទ ការប្រមាថ និងការបៀតបៀន - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **22** | **ការប្រើប្រាស់ឧបករណ៍អេឡិចត្រូនិកមិនសមរម្យ។** សិស្សដែលប្រើគ្រឿងអេឡិចត្រូនិក (ទូរសព្ទដៃ ក្រូមប៊ុក ជាដើម) តាមបែបមិនសមរម្យ ដូចជា៖<br>• ការផ្ញើសារផ្លូវភេទ (ផ្ញើរូបភាព/វីដេអូផ្លូវភេទ)<br>• ការថតការវាយដំ<br>• ការថតនរណាម្នាក់នៅកន្លែងដែលគេរំពឹងថាមានភាពឯកជន<br>• ការបង្ហោះមាតិកាដែលប៉ះពាល់ធំដុំដល់សហគមន៍សាលារៀនដូចជាអាវុធ ឬអាវុធដោយសន្មត | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **ការគំរាមកំហែង និងការបំភិតបំភ័យ - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **23** | **ការគំរាមកំហែង/ការបំភិតបំភ័យ។** សិស្សដែលគំរាមកំហែងចូលធ្វើសកម្មភាពដែលបង្កគ្រោះថ្នាក់ និងនាំឱ្យមានការភ័យខ្លាចចំពោះសមាជិកសហគមន៍ផ្សេងទៀត។ ការគំរាមកំហែងអាចធ្វើឡើងតាមរយៈពាក្យសម្តី សំណេរ កាយវិការ ឬលើប្រព័ន្ធផ្សព្វផ្សាយសង្គម។<br><br>ការបំភិតបំភ័យអាចជាការមើលមិនដាក់ភ្នែក ការតាមដាននរណាម្នាក់ និង/ឬ <u>ដោយចេតនា។</u> ការព្យាយាមធ្វើឱ្យនរណាម្នាក់ភ័យខ្លាច។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **24** | **ការគំរាមកំហែងបែបហិង្សាមហាជន។** សិស្សដែលគំរាមកំហែងចូលធ្វើសកម្មភាពដែលបង្កគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរ ឬបង្កើតជាហានិភ័យធំដុំអាចឱ្យមានគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរដល់សហគមន៍សាលារៀន។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | **ថ្នាក់ទី 6-12** |
| **ការប្រើល្បិចធ្វើបាប និងការចូលរួមក្នុងក្រុមជនពាល - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **25** | **ការប្រើល្បិចធ្វើបាប។** សម្រាប់គោលបំណងផ្តួចផ្តើមឬពង្រឹងសមាជិកភាពរបស់សិស្សណាម្នាក់នៅក្នុងសកម្មភាព/អង្គការសាលារៀន សិស្សដែលធ្វើឱ្យឬបង្ខំឱ្យសិស្សនោះបំពានច្បាប់ព្រហ្មទណ្ឌណាមួយ ប្រើប្រាស់សារធាតុដែលបង្កគ្រោះថ្នាក់ដល់សិស្សនោះ រងភាពឃោរឃៅផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវភេទ ឬប្រព្រឹត្តសកម្មភាពណាមួយដែលបង្កគ្រោះថ្នាក់ដល់អ្នកដទៃ។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **26** | **ការចូលរួមក្នុងក្រុមជនពាល។** សិស្សដែលចូលរួមនៅក្នុងសកម្មភាពគ្រោះថ្នាក់ជំនួសមុខឱ្យក្រុមជនពាលដែលបានកំណត់អត្តសញ្ញាណ ដើម្បីប្រព្រឹត្តបទល្មើសរំខាន ឬខុសច្បាប់នៅក្នុងបរិវេណសាលាជំនួសមុខឱ្យក្រុមជនពាលនោះ។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | **ថ្នាក់ទី 6-12** |
| **ថ្នាំជក់ គ្រឿងញៀន និងគ្រឿងស្រវឹង - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **27** | **ការកាន់កាប់/ការប្រើប្រាស់ថ្នាំជក់។** សិស្សដែលប្រើប្រាស់ ឬកាន់កាប់ថ្នាំជក់ ឬឧបករណ៍ជក់អេឡិចត្រូនិក។ ចំណុចនេះរួមមានជាអាទិ៍ ផលិតផលមានថ្នាំជក់ បារីអេឡិចត្រូនិក ស៊ីហ្គារ vaping និង hookah។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **28** | **ការកាន់កាប់/ប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន។** សិស្សដែលគេរកឃើញថាកាន់កាប់ ឬដែលប្រើប្រាស់គ្រឿងស្រវឹង/គ្រឿងញៀនផ្សេងទៀតជាទម្រង់រាវ/ចំហាយ/ដែលអាចបរិភោគបាន។ | **ថ្នាក់មត្តេយ្យ-ទី 12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 3-12** | **ថ្នាក់ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |

| # | និយមន័យអាកប្បកិរិយា | ការឆ្លើយតបផ្អែកតាមសាលារៀនតែប៉ុណ្ណោះ | ការព្យួរការសិក្សារយៈពេលខ្លី ថ្នាក់ទី 3-12 1-3 ថ្ងៃ | ការព្យួរការសិក្សារយៈពេលវែង ថ្នាក់ទី 3-12 4-10 ថ្ងៃ | ការបញ្ជូនទៅកាន់សវនាការវិន័យ ថ្នាក់ទី 6-12 | ការបណ្តេញចេញ ថ្នាក់ទី 6-12 |
|---|---|---|---|---|---|---|
| **ថ្នាំជក់ គ្រឿងញៀន & គ្រឿងស្រវឹង បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **29** | **ការចែកចាយគ្រឿងស្រវឹង ឬគ្រឿងញៀន។** សិស្សដែលគេ រកឃើញថាកំពុងលក់ និង/ឬ ចែកចាយគ្រឿងស្រវឹង ឬ គ្រឿងញៀនជាទម្រង់រាវ/ដែលអាចបរិភោគបាន។ | **ថ្នាក់ មត្តេយ្យ-ទី 12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 6-12** | **ថ្នាក់ ទី 6-12** |
| **ឧបករណ៍បង្កអគ្គីភ័យ & អាវុធ - បញ្ជូនទៅទីចាត់ការដើម្បីដាក់វិន័យ** | | | | | | |
| **30** | **ការកាន់កាប់/ការប្រើប្រាស់អាវុធ។** សិស្សដែលកាន់កាប់វត្ថុ ឧបករណ៍ ឬសម្ភារៈដែលមានគោលបំណងដើម និង គោលបំណងនៃមុខងាររបស់វាគឺដើម្បីប្រើជាអាវុធ។<br><br><u>អាវុធរួមមាន</u> កាំភ្លើង មិនថាមានគ្រាប់ឬអត់ បង់/ឡូតគ្រាប់ កាំភ្លើង កាំភ្លើងផាវ កាំភ្លើង BB កាំភ្លើងខ្យល់ទន់ គ្រាប់បែក កាំបិត កាំបិតកាត់ប្រអប់ ឧបករណ៍កាត់ ដំបងពីរកំណាត់ ឧបករណ៍ឆក់ ឬដំបង។<br><br><u>អាវុធមិនរួមបញ្ចូលកាំភ្លើងក្មេងលេង</u>បាញ់ទឹកឬដែល ឬវត្ថុធម្មតាៗទេ។ ទាំងនេះអាចចាត់ទុកថាជា "ការបង្កគ្រោះថ្នាក់ដោយប្រហែស" បើប្រើវា/មានបំណងប្រើវាដោយមិនសមស្រប។ | **ថ្នាក់ មត្តេយ្យ-ទី 12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 6-12** | **ថ្នាក់ ទី 6-12** |
| **31** | **ការកាន់កាប់ឧបករណ៍បង្កអគ្គិភ័យ ឬគ្រឿងផ្ទុះ។** សិស្សដែលគេរកឃើញថាកាន់កាប់ឧបករណ៍បង្កអគ្គិភ័យដូចជា ឈើគូស ដែកកេះ កាំជ្រួច ផាវ និង/ឬគ្រឿងផ្ទុះផ្សេងទៀត។ | **ថ្នាក់ មត្តេយ្យ-ទី 12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 6-12** | ការឆ្លើយតបមិនពាក់ព័ន្ធទេ |
| **32** | **ការប្រើប្រាស់ឧបករណ៍បង្កអគ្គិភ័យ ឬគ្រឿងផ្ទុះ។** សិស្សដែលប្រើប្រាស់ ឬបើកដំណើរការឧបករណ៍បង្កអគ្គិភ័យដូចជា ឈើគូស ដែកកេះ កាំជ្រួច ផាវ និង/ឬគ្រឿងផ្ទុះផ្សេងៗ។ ចំណុចនេះអាចរួមមាន ការបង្កឱ្យមានភ្លើងឆេះដោយចៃដន្យ ឬ ដោយចេតនា។ | **ថ្នាក់ មត្តេយ្យ-ទី 12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 3-12** | **ថ្នាក់ ទី 6-12** | **ថ្នាក់ ទី 6-12** |

THE SCHOOL DISTRICT OF PHILADELPHIA

# 2024-2025 ក្រមសីលធម៌

ព័ត៌មាននៅក្នុងសៀវភៅនេះ
អាចត្រូវបានធ្វើបច្ចុប្បន្នភាព
ក្នុងអំឡុងពេលនៃឆ្នាំសិក្សា។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល

**bit.ly/sdpcoc**

School District of Philadelphia មិនរើសអើងនៅក្នុងការងារ ឬកម្មវិធីអប់រំ ឬសកម្មភាពនានា ចំពោះពូជសាសន៍ គោលជំនឿ ពណ៌សម្បុរ ដើមកំណើត សាសនា ពូជពង្ស អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ទំនោរផ្លូវភេទ (ដែលដឹង ឬដែលស្មាន) ការបង្ហាញអត្តសញ្ញាណយេនឌ័រ (ដែលដឹង ឬដែលស្មាន) ភេទ ភាពពិការ ពិការភាព សញ្ជាតិ ពលរដ្ឋ សមាជិកភាពសហជីព ឬជំនាញភាសាអង់គ្លេសមានកម្រិតឡើយ។

គោលនយោបាយគ្មានការរើសអើងនេះ មានវិសាលភាពរហូតដល់ចំណែកថ្នាក់ផ្សេងទៀតទាំងអស់ដែលត្រូវបានការពារដោយច្បាប់។

ការបោះពុម្ពផ្សាយសេចក្ដីជូនដំណឹងនេះ គឺអនុលោមតាមច្បាប់រដ្ឋ និងច្បាប់សហព័ន្ធ រួមមានទាំងចំណងជើង IX នៃវិសោធនកម្មការអប់រំឆ្នាំ 1972 និងផ្នែកទី 503 និង 504 នៃច្បាប់ស្តារនីតិសម្បទាឆ្នាំ 1973។